# អ្នកនាំសារ
## The Messenger



# Education

បន្ទាប់ពីសម័យកាលនៃភាពហិនហោច ដែលមនោគមវិជ្ជាសម្លាប់មនុស្សបានយកបញ្ញវន្តជាតិមកធ្វើជាផ្ទាំងស៊ីប ប្រទេសកម្ពុជាបានចាប់ចេញដំណើរសាជាថ្មី។ ការអប់រំប្រជាជនក្មេងៗ ដែលមាន ៥០% អាយុក្រោម ១៨ ឆ្នាំ គឺជាបញ្ហាសំខាន់ដែលប្រទេសជាតិត្រូវតែស្តារឡើងវិញ។ ដោយចេញដំណើរលើគំនរបាក់បែក ភាពស្វាហាប់ត្រូវមានជាចាំបាច់។ ផែនការស្តារឡើងវិញត្រូវបានលើកឡើង។ ប៉ុន្តែ មានបញ្ហាជាច្រើនដែលបានចោទឡើង គឺថា តើសិស្សទាំងឡាយបានទទួលការអប់រំគ្រប់គ្រាន់ សំរាប់ថ្ងៃអនាគតដែរឬទេ? តើសាលារៀនបានបាត់បង់ដួងព្រលឹងរបស់ខ្លួនដោយសារតែលុយឬទេ?
ក្រុមការងារ "អ្នកនាំសារ" នឹងបង្ហាញអ្នកនូវបញ្ហាទាំងឡាយសំរាប់ពិចារណា។

ពត៌មានពីព្រះសហគមន៍កាតូលិក Internal Use ឆ្នាំទី ០២ លេខ ១៦ ខែ កញ្ញា-តុលា ឆ្នាំ ២០០៤ Photo UNICEF/JONH VINK/MAGNUM

# កម្មវិធីសិក្សាខ្វះនូវគុណភាព

ដោយសារតែសម័យថ្មីនៃសកលភាវូបនីយកម្ម កម្ពុជាត្រូវបានគេកត់សំគាល់ឃើញថា មានវឌ្ឍនភាពយ៉ាងខ្លាំងផ្នែកវិស័យសិក្សាធិការ។ សាលាបណ្តុះបណ្តាល សកលវិទ្យាល័យឯកជន និងរដ្ឋនានា បានឈរបង្អួតគ្នាប្រៀបបីដូចជាផ្សិតរីកនារដូវវស្សា។ ជារៀងរាល់ឆ្នាំ បើតាមកម្មវិធីរបស់អង្គការសហប្រជាជាតិដើម្បីអភិវឌ្ឍន៍ មានយុវជនបញ្ចប់ថ្នាក់ឧត្តមចំនួន ៣៥០០០ នាក់ ប៉ុន្តែ ក្នុងនោះមានយុវជនមិនដល់ ១០% ដែលអាចរកការងារបានធ្វើ។ ទាក់ទងទៅនឹងបញ្ហាខាងលើនេះ ក៏មានសាធារណៈមតិជាច្រើន វាយតម្លៃថា គុណភាពនៃការអប់រំនៅប្រទេសយើងនៅមានកំរិតទាប។ ដោយមានផ្ទៃមុខមាំ និងនិយាយមួយៗ ហើយច្បាស់ៗនោះ លោក រ៉ុន ឈុន ប្រធានសមាគមគ្រូបង្រៀនឯករាជ្យមានប្រសាសន៏ថា "កំរិតស្តង់ដា (បទដ្ឋាន) អប់រំនៅប្រទេស យើងមានភាពទន់ខ្សោយណាស់ បើពិន្ទុរាប់ពី ១-១០ ខ្ញុំសំរេចអោយតែ ២,៥ ទៅ ៣ តែប៉ុណ្ណោះ "។


កំរិតការអប់រំមានពិន្ទុត្រឹម ២,៥ ប៉ុណ្ណោះ

Photo P.Rafaud

លោកបានគូសបញ្ជាក់ទៀតថា "ការធ្លាក់ចុះយ៉ាងដូច្នេះ គឺបណ្តាលមកពីរាជរដ្ឋាភិបាលយើងមិនបានផ្តោតការយកចិត្តទុកដាក់ឱ្យបានខ្លាំងក្លាទៅលើវិស័យនេះ ជាពិសេសសាលារដ្ឋ គឺប្រាក់បៀវត្សរបស់លោកគ្រូ អ្នកគ្រូយើង មិនអាចឆ្លើយតបទៅនឹងកំរិតជីវភាពប្រចាំថ្ងៃបាន ដែលជំរុញឱ្យកើតមានអំពើពុករលុយនៅក្នុងសាលារៀន ដែលប៉ះទង្គិចយ៉ាងធ្ងន់ធ្ងរដល់គ្រូ សារសិស្ស និស្សិតក្រីក្រមួយចំនួនធំ។ ចំណែកឯសាលាឯកជនវិញ រាជរដ្ឋាភិបាលមិនបានគ្រប់គ្រងអោយបានដិតដល់ ចំពោះគុណភាពនៃការបណ្តុះបណ្តាល អំពីកម្មវិធីសិក្សា និងគរុកោសល្យ។ល។ សាលាឯកជនជាច្រើនមានទំរង់ជាផ្ទះល្វែង មានលក្ខណៈចង្អៀត គ្មានកន្លែងសំរាក ខ្វះកន្លែងចតយានយន្ត កីឡដ្ឋាន និងអាហារដ្ឋាន ដែលខុសពីនិយាមគរុកោសល្យ"។ លោកប្រធានសមាគមក៏បានរិះគន់យ៉ាងខ្លាំងក្លាទៀតថា "សិស្សដែលរៀនសូត្រខ្លះ នៅពេល

## ទីផ្សារការងារមិនធំល្មមសំរាប់អ្នកមានសញ្ញាបត្រ



ស្ថានភាពនៃ ទីផ្សារការងារនៅក្នុងប្រទេសកម្ពុជាយើង នាពេលបច្ចុប្បន្ននេះ ហាក់បីដូចជាតូចចង្អៀតមិនឆ្លើយតបទៅនឹង តំរូវការការងាររបស់និស្សិតដែលបានបញ្ចប់ការសិក្សានៅមហាវិទ្យាល័យ ដ៏ច្រើនលើសលប់ពីមួយឆ្នាំទៅមួយឆ្នាំនោះបានឡើយ។

កត្តាខាងលើនេះហើយដែល បានបង្កើតជាចម្ងល់ថា តើវាបណ្តាលមកពីមូលហេតុអ្វី? លោក ឈាង សុខា ដែលជានាយកប្រតិបត្តិនៃអង្គការអភិវឌ្ឍន៏ធនធានយុវជន ព្រមទាំងជាអ្នកមានបទពិសោធន៏ជាច្រើនឆ្នាំជាមួយនិស្សិតខ្មែរប្រមាណជា ២៥ មហាវិទ្យាល័យនៅទូទាំងប្រទេសនោះបានមានប្រសាសន៏ថា: "ភាពគ្មានការងារធ្វើនៅក្នុងសង្គមសព្វថ្ងៃនេះ គឺបណ្តាលមកពីមូលហេតុសំខាន់ៗចំនួន ២ គឺទី ១ មកពីកត្តាសង្គម និងទី ២ គឺកត្តាខ្លួនឯងនេះតែម្តង។ បើនិយាយអំពីកត្តាសង្គម គឺរួមផ្សំឡើងពីស្ថានភាពនយោបាយ សន្តិសុខជាតិ ការវិនិយោគទុន និងក្រុមហ៊ុនឯកជននានា ដែលយើងសង្កេតឃើញថា

មកទល់សព្វថ្ងៃ មិនសូវមានអំណោយផលប៉ុន្មានទេ។ តាមការសង្កេតរបស់ខ្ញុំឃើញថា ប្រទេសយើងជួបប្រទះនូវវិបត្តិនយោបាយជាញឹកញាប់ ដែលជារនាំងមួយរាំងស្ទះដល់កំណើនសេដ្ឋកិច្ចជាតិ ជាពិសេស ក្រុមហ៊ុនវិនិយោគទុនមួយចំនួនធំ គេមិនហ៊ានមកបណ្តាក់ទុននៅប្រទេសកម្ពុជាយើងទេ។ កត្តាទី២នោះ គឺកត្តាខ្លួនឯង និស្សិតយើងភាគច្រើនរៀនមិនបានពូកែ និងមិនមានគោលដៅច្បាស់លាស់ វីមិនចេះភាសាបរទេស។ ម្យ៉ាងទៀតយើងអាចនិយាយថារៀនបង់សំណាញ់ ឬក៏រៀនតាមរបៀបចាប់ឆ្នោត។ ពួកគេរៀនច្រើន ប៉ុន្តែ មិនបានស្វែងរកបទពិសោធន៏អោយបានច្រើននោះទេ ដែលជាហេតុធ្វើឱ្យ ពួកគេមិនអាចប្រកួតប្រជែងជាមួយនិស្សិតបរទេស នៅក្នុងពិភពទីផ្សារការងារសេដ្ឋកិច្ចសេរីនោះបានឡើយ"។

លោកនាយកបានមានប្រសាសន៏បន្តទៀតថា: "និស្សិតយើងភាគច្រើន ពួកគេចូលបំរើការ

ប្រលងលួចចម្លងឯកសារមេរៀន។ សាលាខ្លះមិនបានរឹតបន្តឹងនៅពេលប្រលង គឺបណ្តោយឱ្យសិស្សមួយចំនួនមិនខិតខំរៀនសូត្រ ហើយយោគយល់ដល់សិស្សខ្លាំងពេក មើលទៅហាក់បីដូចជាសកម្មភាពលក់ដូរសញ្ញាបត្រ ឬការបណ្តុះបណ្តាលមានលក្ខណៈជាការវិនិយោគ”។ កត្តាទាំងនេះហើយ ដែលជំរុញឱ្យសិស្សនិស្សិត និងអាណាព្យាបាលមួយចំនួនធំ អស់ជំនឿចិត្តលើវិស័យអប់រំនៅកម្ពុជា។

ចុងបញ្ចប់ លោកប្រធានបានសំណូមពររាជរដ្ឋាភិបាល មេត្តាជួយលើកកំពស់វិស័យអប់រំជាតិឱ្យបានរីកចំរើន ពិសេសតាមរយៈការផ្តល់ប្រាក់បៀវត្សគ្រប់គ្រាន់ដល់គ្រូបង្រៀន និងកែលំអកម្មវិធីអប់រំឱ្យបានល្អ ស្របតាមស្តង់ដារអន្តរជាតិ ដូចប្រទេសមួយចំនួនក្នុងតំបន់។

រ៉ានី ហៀង

ងារនៅតាមស្ថាប័នរដ្ឋ ក្រុមហ៊ុនឯកជន អង្គការក្រៅរដ្ឋាភិបាល និងអង្គការអន្តរជាតិនានា ក្រោយពីពួកគេបញ្ចប់ការសិក្សានៅមហាវិទ្យាល័យ”។

ក្នុងសេចក្តីបញ្ចប់ចុងក្រោយ លោកបានសំណូមពរអោយរាជរដ្ឋាភិបាលយើង មេត្តាជួយពង្រឹងគុណភាពអប់រំដល់និស្សិតខ្មែរនៅគ្រប់មហាវិទ្យាល័យ និងជាពិសេសដល់ប្អូនៗ សូមអោយចេះជួយពង្រឹងគុណភាពដោយខ្លួនឯង ចេះស្វែងរកបទពិសោធន៍ការងារ ចេះបង្កើតទំនាក់ទំនងល្អនៅក្នុងសង្គម ទើបទទួលបានផ្លែផ្កាល្អ ក្នុងការស្វែងរកការងារ។

រ៉ានី ហៀង

Photo D.R

# ការអប់រំនៅកម្ពុជា ២០០០-០៤

























តួលេខមកពីក្រសួងអប់រំ និងអង្គការយូនីសេហ្វ

# “អ្នកចេះបន្តិចបន្តួចបង្រៀន

ខ្ញុំចាប់ផ្តើមធ្វើជាគ្រូបង្រៀនគណិតវិទ្យានៅអនុវិទ្យាល័យ។ នាពេលល្ងាច ខ្ញុំរៀនសូត្រនៅឯសកលវិទ្យាល័យភ្នំពេញ។ ខ្ញុំបានទទួលបរិញ្ញាបត្រប្រវត្តិវិទ្យា។ ជាកាពិតណាស់ មុនចាប់ផ្តើមសង្គ្រាមនាឆ្នាំ ១៩៧០ ខ្ញុំបានចូលរៀននៅសាលាឧត្តមសិក្សាធម្មតា។

នៅឯសកលវិទ្យាល័យសាស្ត្រាចារ្យស្ទើរតែទាំងអស់ គឺជាជនជាតិបារាំង ដូចនៅសាលាឧត្តមសិក្សាធម្មតាដែរ។ គេបង្រៀនយើងមុខវិជ្ជាផ្សេងៗដូចជា គរុកោសល្យ ចិត្តវិទ្យា និងសញ្ញាណខ្លះនៃរដ្ឋបាលគ្រប់គ្រងសាលារៀន។ នៅពេលបញ្ចប់ឆ្នាំសិក្សា យើងអាចក្លាយខ្លួនទៅជាគ្រូបង្រៀននៅតាមវិទ្យាល័យ។ បន្ទាប់មកខ្ញុំចាប់បានប៉ុស្តិ៍ធ្វើការនៅក្នុងវិទ្យាល័យមួយឯក្រុងតាខ្មៅ។ រៀងរាល់ល្ងាចខ្ញុំត្រឡប់មកស្នាក់នៅទីក្រុងភ្នំពេញជាមួយក្រុមគ្រួសារវិញ។ នៅក្នុងឆ្នាំ ១៩៧១ មានការប្រយុទ្ធគ្នាហើយនៅជុំវិញទីក្រុងភ្នំពេញ។ ខ្ញុំទទួលបានប្រាក់ខែ ៧៥០០រៀល ក្នុងនោះរួមបញ្ចូលទាំងថ្លៃស្នាក់នៅផងដែរ។ ខ្ញុំធ្វើការ ១៨ ម៉ោងក្នុងមួយសប្តាហ៍។ ពេលចាប់ផ្តើមនៃសង្គ្រាមប្រាក់ ១ ដុល្លា មានតំលៃស្មើនឹង ៥០ រៀល។

សាលានានាបានបិទទ្វារជាហូរហែរ ក្រោមដំណើររុលទៅមុខនៃកងទ័ពខ្មែរក្រហម។ រាល់កន្លែងរដ្ឋបាលនីមួយៗ ត្រូវមានការស្ម័យការពារ។ គេបានឱ្យកាំភ្លើងមកពួកយើង និងសិស្សដែលត្រូវមកយាមសាលា។ យើងបានឆ្លងកាត់គ្រាមួយដ៏សែនលំបាក។ នៅពេលថ្ងៃយើងបង្រៀន។ នៅពេលយប់យើងយាមកាម។ ពួកខ្មែរក្រហមវាយប្រហារយើងជារឿយៗ ដោយពួកគេគិតថា យើងជាចំណីងាយស្រួលលេប។ សាលារៀនក៏បានទទួលរងដោយគ្រាប់ផ្លោង ដែលបាញ់ដោយពួកខ្មែរក្រហមផងដែរ។

នៅក្នុងឆ្នាំ ១៩៧៣ ខ្ញុំត្រូវបានចាត់តាំងឱ្យធ្វើការនៅភ្នំពេញ។ មនុស្សម្នាបានសំរុកចូលមកទីក្រុងភ្នំពេញ ដោយសារដំណើររុលមករបស់កងទ័ពខ្មែរក្រហមទៀត។ មានគ្រូៗនិងសិស្សានុសិស្សជាច្រើនក៏បានមកដល់ផងដែរ ដែលធ្វើឱ្យមានការខ្វះខាតអគារ។ ដូចនេះ យើងក៏បានចាប់ផ្តើមយកទំលាប់រៀនផ្លាស់ប្តូរវេន ២ ដង ក្នុងមួយថ្ងៃ។




ផែនទីស្រង់ពី សៀវភៅភូមិវិទ្យា ឆ្នាំ១៩៨៣-១៩៨៦

ប្រជាជនតែងតែប្រាថ្នាឱ្យសង្គ្រាម និងរដ្ឋាភិបាលពុករលួយរបស់លោក លន់ នល់ ផុតរលត់។ ពួកគេសង្ឃឹមថា ប្រទេសជាតិនឹងទទួលបានសន្តិភាពសាជាថ្មី។ ចំពោះពួកយើង ពួកខ្មែរក្រហមក៏ជាខ្មែរដែរ និងមានទំនងគោរពសិទ្ធិមនុស្សយ៉ាងពិតប្រាកដ។ យើងគិតថា ដោយមានសម្តេចសីហនុជាប្រមុខដឹកនាំ អ្វីៗនឹងមានដំណើរការអភិវឌ្ឍន៍ឡើងវិញ។

ព័ត៌មាននានាដែលយើងទទួល គឺបានមកពីជនភៀសខ្លួន ឬអ្នកដែលឆ្លងកាត់ទៅមកដើម្បីធ្វើជំនួញជួញដូរលួចលាក់ រវាងទីក្រុងនិងតំបន់គ្រប់គ្រងដោយពួកខ្មែរក្រហម នៅក្រោមការមើលឃើញថា ជាអ្នកសុំមគ្រលុំជាមួយពួកខ្មែរក្រហម។ យើងឮអំពីភាពសាហាវឃោរឃៅរបស់ពួកខ្មែរក្រហមដែរ។ ប៉ុន្តែ យើងមានការសង្ស័យ។ តើនេះជាការពិតដែរឬទេ? យប់មួយ យើងបានឮគេនិយាយថា មានការទំលាក់អាវុធចុះចាញ់ ក្រោយពីមានការចរចារួចហើយ។ ១ ថ្ងៃបន្ទាប់ពីថ្ងៃទី ១៧ មេសា ១៩៧៥ ប្រជាជនទីក្រុងភ្នំពេញ បានចុះទៅលើដងវិថី ដើម្បីទទួលពួកខ្មែរក្រហម ដោយ

# អ្នកដែលមិនចេះសោះ”






Photo D.R

មុនឆ្នាំ ១៩៧៥ ជាពេលវេលាគ្មានក្តីបារម្ភណ៍ !

គ្រវីក្រណាត់ពណ៌សជាសញ្ញានៃការទទួលរាក់ទាក់។ ប៉ុន្តែភ្លាមនោះ មនុស្សម្នាមានការប៉ះទង្គិចចិត្តយ៉ាងខ្លាំង ដោយឃើញការសំដែងទឹកមុខកាចសាហាវរបស់ពួកទាហាន។ ពួកគេទាំងនោះសំដែងអារម្មណ៍ ដូចជាបានចូលក្នុងប្រទេសមួយដែលគេដណ្តើមបាន។

ខ្ញុំត្រូវបានគេបណ្តេញចេញជាមួយនឹងប្រជាជននៃភូមិកំនើតរបស់ខ្ញុំ។ គេបានសាកសួរខ្ញុំថាតើខ្ញុំមានមុខរបរអ្វីក្នុងរបប លន់ នល់។ ខ្ញុំបានកុហកនិងប្រាប់ថា ខ្ញុំជាគ្រូបង្រៀនសាមញ្ញម្នាក់។ ក្នុងអំឡុងប៉ុន្មានឆ្នាំនោះ គ្មាននរណាម្នាក់គេស្អប់ខ្ញុំនោះទេ។ នៅសម័យនោះ សាលារៀនត្រូវបានបិទទ្វារទាំងអស់។ មនោគមវិជ្ជារបស់ពួកខ្មែរក្រហម គឺថា ជនបទគឺជាសាលាហើយវាលស្រែគឺជាសៀវភៅ។

ក្រោយរបបខ្មែរក្រហម ប្រហែលជាខែមីនា ឆ្នាំ ១៩៧៩ ខ្ញុំបានត្រឡប់មកកាន់ទីក្រុងភ្នំពេញវិញ។ ពួកគេបានបំផ្លាញនិងទុកចោលឱ្យធុំក្លិនអសោចិ៍នូវសាលារៀន ដោយប្រែក្លាយសាលារៀនទៅជាទ្រុងជ្រូក គុក ឬកន្លែងផលិតជី។ អគារនានាមាននៅសល់តិចតួចណាស់។ ហើយគ្រូបង្រៀនមួយចំនួនដែលរស់រានមានជីវិតរស់នៅរប៉ាត់រប៉ាយ។ គ្រូបង្រៀនជាច្រើនត្រូវបានគេសម្លាប់។ ខ្លះទៀតត្រូវបានគេនិរ-ទេសខ្លួន។ គេត្រូវតែស្តារនិងកសាងប្រទេសជាតិ ដោយចេញដំនើរពីលេខសូន្យឡើងវិញ។ ខ្ញុំបានចូលធ្វើការនៅមជ្ឈមណ្ឌលរៀបចំកម្មវិធី និងសៀវភៅសិក្សា។ បំណងសំខាន់ទី ១ របស់យើង គឺកោះហៅឱ្យវិលត្រឡប់មកវិញ នូវអ្នកដែលចេះអាននិងសរសេរ ដើម្បីទាំងអស់គ្នា រដ្ឋាភិបាលជនជាតិវៀតណាម និងអ្នករស់រានមានជីវិត។ យើងត្រូវតែបើកឱ្យដំនើរការនូវសាលារៀនឡើងវិញ។ ការលុបបំបាត់អនក្ខរភាពនៃមនុស្សធំ គឺជាអាទិភាពមួយក្នុងចំណោម អាទិភាពទាំងឡាយរបស់យើង។ កម្មវិធីសិក្សាត្រូវបានរៀបចំឡើងដោយឈរលើមូលដ្ឋាននៃកម្មវិធីកុម្មុយនិស្ត។ មានការពិភាក្សាគ្នាជាមួយនឹងអ្នកជំនាញការ វៀត ណាម លើការប្រៀបធៀបអត្ថន័យរបស់កម្មវិធី។ ឧទាហរណ៍ ក្នុងមុខវិជ្ជាភូមិវិទ្យា និងប្រវត្តិវិទ្យាមានការតវ៉ាគ្នា។ ដូចនេះ ប្រវត្តិសាស្ត្រមិនត្រូវបានគេបង្រៀនទេ។ គេរីករាយបង្រៀនអំពីសីលធម៌នយោបាយ។ ពេលនោះ គ្មានពេលវេលាដើម្បីបណ្តុះបណ្តាលគ្រូបង្រៀនទេ អ្នកស្ម័គ្រចិត្តចាប់ផ្តើមការងារភ្លាមដោយដូរយកអង្ករ។ ពួកគេទទួលយកនូវការបណ្តុះបណ្តាលគរុកោសល្យនៅពេលវិស្សមកាល។

បន្តិចម្តងៗ យើងបានទទួលជោគជ័យលើការបណ្តុះបណ្តាលពួកគាត់ មុននឹងពួកគាត់ចូលបង្រៀន។ មុនដំបូងគ្មានសាលារៀនគ្រប់គ្រាន់ទេ។ គេត្រូវបង្រៀននៅក្រោមផ្ទះ ឬនៅក្រោមម្លប់ឈើ។ សំរាប់ក្តារខៀន គេយកតុបញ្ឈរឡើង ឬទ្វារមួយគឺគ្រប់គ្រាន់។ ចំណែកដីសសរសេរ គេប្រើប្រាស់ធ្យូង។ សាលារៀនមានដល់ថ្នាក់ទី ៧។ មេរៀនដែលយកពីអត្ថបទវាយអង្គុលីលេខត្រូវបានផ្ញើទៅឱ្យគ្រូ។ ពួកគាត់បង្រៀនដោយគ្មានសៀវភៅពុម្ព។ គេជ្រើសរើសអ្នកដែលបញ្ចប់សាលាបឋម ដើម្បីបណ្តុះបណ្តាលឱ្យក្លាយទៅជាគ្រូបង្រៀន។ អ្នកដែលបង្រៀននៅមធ្យមសិក្សា ត្រូវមានកំរិតបញ្ចប់មធ្យមសិក្សាកំរិតមួយ។ សកលវិទ្យាល័យមិនទាន់បើកទ្វារឱ្យដំនើរការនៅឡើយទេនាពេលនោះ។

ក្រោយឆ្នាំ ១៩៧៩ យើងចេញដំនើរលើគោលការណ៍ដូចតទៅនេះ “អ្នកដែលចេះតិចបង្រៀនអ្នកដែលមិនចេះ ហើយអ្នកដែលចេះច្រើនបង្រៀនអ្នកដែលចេះតិច”។

នៅឆ្នាំ ១៩៨៩ កងទ័ពវៀតណាមបានធ្វើមាតុភូមិនិវត្តន៍វិលត្រលប់ទៅកាន់ប្រទេសកំណើតខ្លួនវិញ។ វិស័យអប់រំក៏បានបើកទំព័រសករាជថ្មីរបស់ខ្លួននៅលើទឹកដីកម្ពុជា។

សូមថ្លែងអំណរគុណលោក ស៊ុនហេង ម៉េងឈាង!

PR

## មតិអាណាព្យាបាលសិស្ស

ប្រទេសកម្ពុជាទើបរួចផុតពីភ្លើងសង្គ្រាម។ ប្រជាជនភាគច្រើនមានជីវភាពក្រតោកយ៉ាក ដែលជាឧបសគ្គយ៉ាងធំ ក្នុងការបញ្ជូនកូនចៅឱ្យទៅរៀន។ ម្យ៉ាងវិញទៀត ប្រពៃណីក៏ជារបាំងមួយ ដែលជំរុញឱ្យអាណាព្យាបាលដាក់កំរិតលើការសិក្សារបស់កូនស្រីដែរ។ ឆ្លើយតបទៅនឹងបញ្ហាខាងលើនេះ អ៊ំស្រី សុភិន វិសាល អាយុ ៤២ ឆ្នាំ ជាប្រជាពលរដ្ឋម្នាក់នៅទីក្រុងភ្នំពេញបានថ្លែងថា "ខ្ញុំមានបំណងយ៉ាងមោះមុត ដើម្បីបញ្ជូនកូនខ្ញុំឱ្យទៅរៀន ទោះបីជាខ្ញុំមានជីវភាពលំបាកក៏ដោយ។ ខ្ញុំសុខចិត្តធ្វើការងារលំបាកៗ ដើម្បីអោយពួកគេបានរៀនសូត្រ ពីព្រោះការសិក្សា មានសារៈសំខាន់ណាស់ទៅថ្ងៃអនាគត"។ អ៊ំស្រីបានបន្តទៀតថាៈ "រាល់ថ្ងៃខ្ញុំត្រូវចំណាយប្រាក់ច្រើន ឱ្យកូនទាំងបីនាក់របស់ខ្ញុំរៀនគួរផ្សេងៗ ទិញឯកសារសិក្សា និងសំលៀកបំពាក់ជាដើម។ ជានិច្ចកាល ខ្ញុំតែងតែព្រួយបារម្មណ៏ចំពោះកូន នៅពេលពួកគេបញ្ចប់ការសិក្សានៅមធ្យមសិក្សា និងបន្តទៅមហាវិទ្យាល័យ ពីព្រោះបន្ទុកចំណាយនឹងឡើងខ្ពស់។ ទោះបីជាមានឧបសគ្គយ៉ាងនេះក្តី ខ្ញុំត្រូវតែតស៊ូឱ្យកូនរបស់ខ្ញុំ បានបញ្ចប់ការសិក្សាជាស្ថាពរ ហើយខ្ញុំក៏មានក្តីសង្ឃឹមថា កូនរបស់ខ្ញុំទាំងបីនាក់ នឹងមានអនាគតភ្លឺស្វាង ដោយមានការងារល្អ។ នេះជាបំណងប្រាថ្នា និងក្តីស្រមៃរបស់ខ្ញុំ ក្នុងនាមជាមាតាម្នាក់"។ សរុបមក អាណាព្យាបាលទាំងអស់ គួរតែលើកទឹកចិត្ត និងជំរុញឱ្យកុលបុត្រកុលធីតារបស់ខ្លួន បានសិក្សារៀនសូត្រគ្រប់ៗគ្នា ពីព្រោះយុវជនគឺជាទំពាំងស្នងឫស្សី។

រ៉ានី ហៀង



# រឿងរ៉ាវជាទំលាប់ទាក់

## "ស្ថានភាពការអប់រំនៅកម្ពុជានាពេលបច្ចុប្បន្នៈ ការរៀនសូត្ររបស់សិស្សានុសិស្ស"

រយៈពេលប៉ុន្មានឆ្នាំមកនេះ វិស័យអប់រំនៅប្រទេសកម្ពុជាបានរីកចំរើនលើគ្រប់ផ្នែក ជាពិសេស គឺកម្មវិធីសិក្សាដែលឆ្លើយតបបានទៅនឹងតំរូវការផ្នែកចំណេះដឹងនៃសិស្សានុសិស្ស។ ដោយទឹកមុខស្រស់ញញឹម ប្អូនស្រី កួយ ដាណែត អាយុ ១៦ ឆ្នាំ រៀនថ្នាក់ទី ១២ នៃវិទ្យាល័យពោធិ៍សាត់ បានរៀបរាប់ប្រាប់អ្នកនាំសារថាៈ "ខ្ញុំសប្បាយចិត្តទៅនឹងការសិក្សា។ រវាងមុខវិជ្ជាទាំងអស់ ខ្ញុំស្រឡាញ់ភាសាអង់គ្លេសជាងគេ ពីព្រោះដោយបច្ចុប្បន្ននេះ ប្រទេសយើងសំបូរអ្នកទេសចរណ៏ អ្នកវិនិយោគ និងអង្គការក្រៅរដ្ឋាភិបាល ដែលភាសាអង់គ្លេសត្រូវបានគេប្រើដើម្បីទាក់ទងគ្នា"។ ប្អូនស្រីបានបន្តថាៈ "បញ្ហាលំបាក គឺខ្ញុំត្រូវចាយលុយច្រើនដើម្បីរៀនគួរបន្ថែម ទិញមេរៀន និងក្រដាសថតចម្លងផ្សេងៗនៅពេលប្រលងម្តងៗ"។ ចំណែកប្អូនប្រុស កុល ញ៉ អាយុ ១៨ ឆ្នាំ រៀននៅវិទ្យាល័យសន្តប្រូង់ស្វ័រ នៃព្រះសហគមន៏កាតូលិកចំការទៀងមានយោបល់ថាៈ "ការសិក្សាជាក្តីប្រាថ្នាខ្ញុំតាំងពីកុមារភាព។ ក្នុងចំណោមមុខវិជ្ជាទាំងអស់នៅសាលា ខ្ញុំពេញចិត្តមុខវិជ្ជាភាសាអង់គ្លេសជាងគេ ពីព្រោះជាភាសាអន្តរជាតិ ដែលអាចឱ្យយើងងាយស្រួលរកការងារធ្វើ។ ចំពោះការសិក្សានាពេលបច្ចុប្បន្ន ខ្ញុំមានការលំបាកលើថវិកាសំរាប់រៀនគួរ និងទិញឯកសារបន្ថែម។ ម៉ោងសិក្សានៃវិទ្យាល័យ គឺមានគ្រប់គ្រាន់ ពេលព្រឹកពីម៉ោង ៧ ដល់ ម៉ោង ១១ និងរសៀលពីម៉ោង ១ ដល់ម៉ោង ៥ ។ ចំណែកគ្រូមានទេពកោសល្យនិងបង្រៀនល្អ"។ ប្អូនប្រុស សុវណ្ណ ពិសិដ្ឋមុន្នី អាយុ ១៧ ឆ្នាំ រៀនថ្នាក់ទី ១២ នៃវិទ្យាល័យទួលទំពូង ក្រុងភ្នំពេញបាននិយាយថាៈ "ខ្ញុំចាប់អារម្មណ៏យ៉ាងខ្លាំងលើការសិក្សា ពីព្រោះវាអាចធ្វើឱ្យអនាគតខ្ញុំភ្លឺស្វាង។ សំរាប់មុខវិជ្ជាទាំងអស់ ខ្ញុំស្រឡាញ់គណិតវិទ្យាជាងគេ ពីព្រោះមុខវិជ្ជានេះ អាចឱ្យខ្ញុំងាយស្រួល ប្រលងយកអាហារូបករណ៏ទៅសិក្សានៅបរទេសបាន។ ការសិក្សាក្នុងសាលាមិនសូវជាល្អប៉ុន្មានទេ ដូចនេះដើម្បីឱ្យមានភាពរីកចំរើននោះ ខ្ញុំត្រូវរៀនគួរបន្ថែមឱ្យបានច្រើនជាពិសេសលើមុខវិជ្ជាគណិតវិទ្យា និងរូបវិទ្យាជាដើម"។

ជាចុងក្រោយ ប្អូនទាំងបីរូបបានសំណូមពរទៅក្រសួងអប់រំយុវជននិងកីឡា ពិសេសទៅរាជរដ្ឋាភិបាលកម្ពុជា ឱ្យជួយលើកស្ទួយវិស័យសិក្សាធិការជាតិ ដោយបង្កើតនូវកម្មវិធីសិក្សាថ្មី ផ្តល់អាហារូបករណ៏ដល់សិស្សនិស្សិតក្រីក្រឱ្យបានច្រើន និងបង្កើនម៉ោងសិក្សាផងដែរ។

រ៉ានី ហៀង



UNICEF/JONH VINK/MAGNUM

# ទងទៅនឹងសាលារៀន

## ជីវិតគ្រូបង្រៀនប្រឈមមុខនឹងស្ថានភាពសង្គម

ក្នុងសង្គមខ្មែរសព្វថ្ងៃ គ្រូបង្រៀនហាក់បីដូចជាឃ្លាតឆ្ងាយពីចំណាប់អារម្មណ៍ នៃមជ្ឈដ្ឋានប្រជាជនគ្រប់ស្រទាប់ ដោយសារកំរិតជីវភាពរបស់ពួកគាត់ភាគ ច្រើនលំបាកតោកយ៉ាក។ តើលោកគ្រូ អ្នកគ្រូ យើងបានប្រឈមមុខនឹងបញ្ហាអ្វីខ្លះ? អ្នកគ្រូ អ៊ឹម សីវផា អាយុ ៣៥ ឆ្នាំ ដែលមានបទពិសោធន៍ក្នុងការបង្រៀន រយៈពេល ២២ ឆ្នាំ នៅសាលាបឋមសិក្សាទួលទំពូង បានមានប្រសាសន៍ថា: “បច្ចុប្បន្ននេះជីវភាពខ្ញុំគឺយ៉ាប់យ៉ឺនណាស់ ដោយសារប្រាក់ខែមិនគ្រប់គ្រាន់ គឺប្រមាណជា ១០ ម៉ឺនរៀលប៉ុណ្ណោះ។ ខ្ញុំត្រូវចំណាយប្រាក់ជាច្រើនលើការរៀនសូត្ររបស់កូនចៅ លើទឹកភ្លើង និងអាហារប្រចាំថ្ងៃ”។ អ្នកគ្រូបានបន្ថែមទាំងទឹកមុខស្រពោនថា: “ក្រៅពីការបង្រៀន ខ្ញុំមិនមានមុខរបរផ្សេងទៀត ដើម្បីរកប្រាក់កំរៃបន្ថែមទៀតបានឡើយ។ នៅពេលមានជំងឺ ខ្ញុំមិនមានប្រាក់ដើម្បីព្យាបាលជំងឺឡើយ។ ចំពោះការបើកបង្រៀនគួរបន្ថែម ជួបប្រទះការលំបាកណាស់ ដោយសារតែសិស្សមួយចំនួនធំមាន ជីវភាពក្រីក្រ មិនមានលទ្ធភាពបង់លុយ”។ ចំពោះគុណភាពនៃការសិក្សានាពេលបច្ចុប្បន្នវិញ អ្នកគ្រូបានចាប់អារម្មណ៍ថា: “ជាទូទៅ ខ្ញុំសង្កេតឃើញថា សិស្សភាគច្រើនរៀនពូកែ មានប្រមាណ ៧៥%។ នេះដោយសារតែមានកិច្ចសហប្រតិបត្តិការរវាងបណ្តាអង្គការក្រៅរដ្ឋាភិបាលនានា ដូចជាអង្គការវ៉េតបាណា ដែលបានផ្តល់ឯកសារល្អៗ និងជួយបណ្តុះបណ្តាលគ្រូបង្រៀនជាច្រើនវគ្គទៀតផង”។

ជាចុងក្រោយ អ្នកគ្រូបានសំណូមពរដល់រដ្ឋាភិបាល មេត្តាគិតគូរដល់គ្រូបង្រៀនផង។

រ៉ានី ហៀង

## ការវាយតម្លៃរបស់សិស្សលើការអប់រំសព្វថ្ងៃ

យុវសិស្ស ណារី ជាសិស្សថ្នាក់ទី ១២ សិក្សានៅសាលា នៃអង្គការដើម្បីភាពញញឹមរបស់កុមារ។ នាងទើបតែប្រលងបាក់ឌុបថ្មី។ នាងបានបញ្ចេញទស្សនៈផ្ទាល់ខ្លួនរបស់នាង ចំពោះការប្រឡង និងការអប់រំ នៅប្រទេសយើងសព្វថ្ងៃនេះថា “សិស្សដែលចូលរួមប្រលងភាគច្រើន មិនបានធ្វើ ដោយសមត្ថភាពខ្លួនឯងទេ គឺពួកគេបើកមើលប្រ៊ុយយ៉ុង និងមើលគ្នាទៅវិញទៅមក។ នាងគិតថា បើការប្រលងនៅតែមានភាពធូររលុងដូចនេះរាល់ៗឆ្នាំនោះ សិស្សានុសិស្សនឹងពុំខិតខំរៀនឡើយ។ ចំពោះការអប់រំសព្វថ្ងៃ គឺនៅមានការខ្វះខាត និងមានការអន់ថយនៅឡើយ ដោយសារប្រទេសយើងជាប្រទេសក្រីក្រ ខ្វះមណ្ឌលអប់រំ ហើយរដ្ឋាភិបាលមិនបានផ្តល់ប្រាក់បៀវត្សគ្រប់គ្រាន់ដល់គ្រូបង្រៀន ដូចនេះហើយធ្វើឱ្យការអប់រំមានការថយចុះ”។ ជាចុងបញ្ចប់ នាងសូមសំណូមពរ និងផ្តល់ជាការលើកទឹកចិត្តខ្លះថា: “សូមអោយសិស្សទាំងអស់ខិតខំរៀនសូត្រ ទទួលចំណេះដឹងដោយខ្លួនឯង ទោះបីជាយើងទទួលបានពិន្ទុតិច រឺប្រលងធ្លាក់ ក៏យើងបានបង្ហាញពីសមត្ថភាពផ្ទាល់ខ្លួនរបស់យើងហើយដែរ។

ចំណែកយុវសិស្ស រិទ្ធ រៀននៅវិទ្យាល័យព្រះស៊ីសុវត្ថិ ថ្នាក់ទី ១២ ក៏បាននិយាយពីការប្រលង និងការអប់រំនាពេលបច្ចុប្បន្ននេះដែរថា “មានកំរិតទាប ដោយសារតែគ្រូមិនសូវយកចិត្តទុកដាក់ក្នុងការបង្រៀន គឺគ្រាន់តែមកលក់មេរៀនអោយសិស្សរួចត្រលប់ទៅវិញ បើពួកគេចង់ដឹងច្រើនជាងនេះ ទាល់តែទៅរៀនគួរ ទើបគ្រូបង្រៀនបានជិតដល់។ ចំណែកការប្រលងនៅមានភាពធូររលុង ដោយសិស្សឱ្យលុយគ្រូដើម្បីអាចមើលគ្នា រឺមើលប្រ៊ុយយ៉ុង។ ខ្ញុំមិនបានបញ្ចេញសមត្ថភាពផ្ទាស់ឱ្យបានពេញលេញទេ ដោយពឹងលើប្រ៊ុយយ៉ុងខ្លះដែរ។

ក.គន្ធា

# អំពើហិង្សាប្រចាំថ្ងៃនៅសាលារៀន

ការគំរាមយកប្រាក់ ការលួច បាតុភូតក្រុមបងធំ ហាក់ដូចជាថយចុះយ៉ាងខ្លាំង ដោយសារតែការត្រួតពិនិត្យយ៉ាងសកម្មរបស់គ្រូបង្រៀន និងអាជ្ញាធរមូលដ្ឋាន។ ដំណោះស្រាយនៃអំពើអសកម្មទាំងនេះ បានប៉ះទង្គិចយ៉ាងយូរទៅនឹងផលប្រយោជន៍សង្គម របស់ជនកំណាចឃោរឃៅ ក្មេងៗទាំងនេះដែលអាចជាកូនរបស់អ្នកមានបណ្ដាសក្តិ ដែលតែងមានមនោសញ្ចេតនាអធ្យាស្រ័យទោស និងក្មេងដែលឈប់រៀននិងត្រូវកាត់ផ្ដាច់ចេញពីសង្គម។ នៅឆ្នាំ ២០០០ សាលាក្រុមភ្នំពេញបានសំរេចចិត្ត ពង្រឹងកិច្ចសហប្រតិបត្តិការនៅក្នុងវិទ្យាល័យនានា រវាងប៉ូលីសនិងមន្ត្រីអប់រំ។ ៤ ឆ្នាំក្រោយមក បទល្មើសហាក់ដូចជាបានថយចុះ។ លោក ពៅ ពិដោរ ដែលជាអនុប្រធានប៉ុស្តិ៍ សង្កាត់ទួលស្វាយព្រៃ ២ និយាយអំពីការឃាត់ខ្លួន ១២ករណីរវាងពីដំណាច់ឆ្នាំ ២០០៣ ដល់ខែមេសា ឆ្នាំ ២០០៤ សំរាប់វិទ្យាល័យតែមួយក្នុងសង្កាត់។ គាត់បញ្ជាក់ទៀតថាៈ "ប៉ុន្តែ ចាប់ពីឆ្នាំ ២០០២ បទល្មើសនៅសាលារៀន បានធ្លាក់ចុះអស់៨០% ហើយប៉ូលីស ២ នាក់ កំពុងតែឃ្លាំមើល"។ ប៉ូលីសសន្និដ្ឋានដូចនាយកជាច្រើននៃគ្រឹះស្ថាននានាថា "គ្រឿងញៀន គឺជាមូលហេតុមួយក្នុងចំណោមមូលហេតុសំខាន់ៗនៃអំពើហិង្សា"។ ទណ្ឌកម្មដូចជាការបណ្ដេញចេញពីសាលា មិនអាចដោះស្រាយបញ្ហាបានទាំងអស់នោះទេ។ សិស្សម្នាក់នៃវិទ្យាល័យបាក់ទូក បានរៀបរាប់ថាៈ "សិស្សសាលាដែលគេបណ្ដេញចេញ ត្រឡប់មកវិញទារលុយពីពួកយើង។ ប្រសិនបើយើងបដិសេធ ពួកគេវ៉ាយយើង"។ ប្អូននិយាយបែបនេះ ប៉ុន្តែ ក៏បានទទួលស្គាល់ថា មានការថយចុះនូវបាតុភូតនេះផងដែរ។ អ្នកបង្កបញ្ហាខ្លះគឺជាសិស្សដែលកំពុងរៀនតែម្ដង។

ឧទាហរណ៍ វិចិត្រ អាយុ ២១ ឆ្នាំ ដែលគំរាមទារលុយពីមិត្តភក្តិរបស់ខ្លួន ដើម្បីយកទៅផឹកស៊ី បន្ទាប់ពីម៉ោងរៀន។ លោកនាយកសាលាខាត ដា រចនា បានរៀបរាប់ឱ្យដឹងថាៈ "កាលពីខែធ្នូ វាបានវ៉ាយតប់លើសិស្សម្នាក់ដែលបដិសេធមិនឱ្យលុយ។ ប៉ូលីសម្នាក់បានទៅផ្ទះវា ឳពុកវាដែលជាអតីតយោធិនម្នាក់ នឹងគេដែរនោះបានសារភាពថា គាត់លែងមានអំណាចលើកូនរបស់គាត់ទៀតហើយ"។



## អំពើពុករលួយនៅសាលា

ចាប់តាំងពីឆមាសទី ១ នៅថ្នាក់ទី ១២ ការសស្រាក់សស្រាំធ្វើអ្វីៗគ្រប់យ៉ាង ដើម្បីទទួលបាននូវសញ្ញាបត្រធាក់ឌុបចាប់ផ្ដើម។ គ្រូមួយចំនួនទាមទារប្រាក់ពី ២០ ទៅ ៥០ ដុល្លា ពីសិស្សរបស់ខ្លួន ដោយសន្យាផ្ដល់ពិន្ទុល្អ។ ការប្រលងជាប់បាក់ឌុបពឹងផ្អែកទៅលើ ៨០% នៃពិន្ទុពេលប្រលង និង ២០% ទៀតជាលទ្ធផលដែលបានមកពីការសិក្សាប្រចាំឆ្នាំ។ យុវសិស្សនារីម្នាក់នៃវិទ្យាល័យបាក់ទូករៀបរាប់ប្រាប់ថាៈ "ពីដំបូងខ្ញុំមានការងឿងឆ្ងល់យ៉ាងខ្លាំងថា សិស្សដែលអវត្តមានជារឿយៗ នៅតែទទួលបានពិន្ទុល្អ។ ឥលូវខ្ញុំដូចគ្នា ខ្ញុំត្រូវចំនាយប្រាក់ ២០ ដុល្លា ដើម្បី

ទទួលបានពិន្ទុល្អ”។ សិស្សនៃវិទ្យាល័យព្រះស៊ីសុវត្ថិម្នាក់ បានកត់សំគាល់ឃើញថា ភាគច្រើននៃមិត្តភក្តិរបស់ខ្លួន ដែលជាកូនអ្នកមាន មានវត្តមានភាគច្រើនតែនៅថ្ងៃប្រលងតែប៉ុណ្ណោះ។ “រឿងហ្នឹង មិនធ្វើឱ្យខ្ញុំទាស់ចិត្តអ្វីទាំងអស់។ អំពើពុករលួយមានមែន។ ប៉ុន្តែ ខ្ញុំនៅតែជឿជាក់ថា ចំណេះដឹងមានតំលៃជាងប្រាក់កាក់ជាដរាប។ ខ្ញុំខំរៀនហើយ ខ្ញុំនឹងឈានទៅទទួលបានលទ្ធផលល្អ”។ លោកគ្រូមួយចំនួនក៏បានគូសបញ្ជាក់ក្នុងអត្ថន័យដូចគ្នាផងដែរ។ លោកគ្រូម្នាក់ដែលបង្រៀនមុខវិជ្ជាគីមី នៅទីក្រុងភ្នំពេញបានពន្យល់ថាៈ “ខ្ញុំខិតខំជាដរាប ដើម្បីលើកទឹកចិត្តដល់សិស្សរបស់ខ្ញុំឱ្យខិតខំរៀន និងកុំគិតចង់បានសញ្ញាបត្រដោយងាយស្រួល ឬដោយសារតែប្រាក់នោះ”។

នៅថ្ងៃប្រលង ឧត្តមបានត្អូញត្អែរ។ ឯកសារសំរាប់លបមើលគេប្រមូលយកអស់ នៅពេលគេមកដល់ក្នុងថ្នាក់។ “ខ្ញុំបានចំណាយលុយ ៥០០០ រៀលទៅអនុរក្ស ប៉ុន្តែ ពួកគាត់នៅតែប្រមូលប្រ៊ុយយ៉ុងយកទាំងអស់”។ ពីចំមុខវិទ្យាល័យបឹងត្របែក ស្ត្រីឈរម្នាក់បានជេរប្រមាថប៉ូលីស និងអនុរក្ស ដែលហ៊ានចាប់យកប្រ៊ុយយ៉ុងរបស់កូនស្រីគាត់។ គាត់បាននិយាយថា “ខ្ញុំបានចំណាយអស់ ២០ ដុល្លា ដើម្បីឱ្យកូនស្រីរបស់ខ្ញុំអាចលួចមើលឯកសារ ដោយសេរី ប៉ុន្តែ វាគ្មានបានប្រយោជន៍អ្វីទាល់តែសោះ”។ នៅពេលចេញពីប្រលងបាក់ឌុប សិស្សៗខ្លះនិយាយថា នៅក្នុងថ្នាក់របស់ពួកគេ អនុរក្សបានស្នើសុំលុយ ១០០ ដុល្លា ដើម្បីឱ្យពួកគេអាចធ្វើអ្វីៗតាមចិត្ត ដូចជាលបមើល ពិភាក្សាគ្នា ហើយអនុរក្សជួយធ្វើជាអ្នកឃ្លាំមើលអ្នកត្រួតពិនិត្យ និងអ្នកទទួលខុសត្រូវមណ្ឌលប្រលង នៅពេលដែលពួកគេធ្វើដំណើរដើរមកជិត។

ដកស្រង់ពី កំបូដ ស័រ

# សីលធម៌ធ្វើឱ្យបុគ្គលមានសុភមង្គល




បណ្ឌិត ឡៅ ម៉ុងហៃ
(មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម)


**អ្នកនាំសារៈ** តើតម្លៃអ្វីខ្លះដែលក្មេងៗបានទទួលបន្ថែមពីការអប់រំក្នុងសាលារៀន?

**លោកបណ្ឌិតៈ** តាមបទពិសោធន៍ផ្ទាល់ខ្លួនរបស់ខ្ញុំ ការអប់រំក្នុងគ្រួសារអាណាព្យាបាលគួរតែប្រយត្ន័ពាក្យសំដី កុំប្រទុចបង្អាក់ក្មេងដូចជាថាៈ “កុំចេះជាងអញ” សូវឱ្យវានិយាយប្រាប់យើងវិញ។ ក្មេងជាមនុស្សទន់ខ្សោយ ឆាប់ខ្លាច គួរកុំបន្លាចវាបន្ថែម ដូចជាពេលវាយំ យើងមិនរកមូលហេតុថា យំដោយសារខ្លាចរឺដោយសារឈឺ ជួនកាលបែរជាវាយវាទៀត។ នេះការអប់រំក្នុងគ្រួសារឃើញថាយើងគិតមិនដល់ អាងតែក្មេងមិនចេះគុំ យើងចេះតែថាឱ្យវាទៅ ដល់ពេលវាធំឡើងទៅជាមនុស្សឆាប់ឆែវឆាវ។ ដូច្នេះ ក្នុងគ្រួសារយើងត្រូវយល់ថា ឥឡូវមានការពិបាកអប់រំខាងសីលធម៌ មិនដូចពីមុនទេ។ ពីដើមខ្ញុំរៀនបាន ច្រើនអំពីសីលធម៌។

**អ្នកនាំសារៈ** តើធ្វើយ៉ាងណា ដើម្បីអាចប្រកាន់ខ្ជាប់នូវសីលធម៌ល្អបាន?

**លោកបណ្ឌិតៈ** សីលធម៌! ខ្ញុំចែកសាលារៀនមានដូចជា នៅផ្ទះ សាលារៀន និងកន្លែងធ្វើការ។ ខ្ញុំលើកបញ្ហាសង្គមមួយ។ ភ្នាក់ងារនគរបាលមានការអប់រំពិសេសទទួលខុសត្រូវសណ្តាប់ធ្នាប់ អាចជាគំរូល្អ រឺអាក្រក់។ យុវជនឃើញនគរបាលចាប់អ្នកដែលចតឡានខុសកន្លែង ប៉ុន្តែមិនចាប់អ្នកដែលមិនគោរព ភ្លើងក្រហម រឺអ្នកដែលជិះបញ្ច្រាស់ ធ្វើដូចនេះ អ្នកដ៏ទៀតឃើញយល់ថា នគរបាលឥតចាប់ផងយើងទៅវិលវល់ធ្វើអី។ ដូចនេះបើអ្នកច្បាប់ត្រូវធ្វើឱ្យ គេគោរពច្បាប់។ យើងធ្វើឱ្យវាហួតប្រែទៅ ក្មេងវាឃើញថា ម្នាក់នេះធ្វើល្អ វានឹងយកធ្វើជាគំរូតាម។

**អ្នកនាំសារៈ** តើគេអាចរកឃើញតំលៃនៃសីលធម៌នៅក្នុងការងារដែរឬទេ?

**លោកបណ្ឌិតៈ** ប្រាកដណាស់! កាលខ្ញុំនៅជាយុវជនទើបនឹងចេញធ្វើការ។ យើងសន្មត់ថា ជួយធ្វើការ ប៉ុន្តែ យើងធ្វើទៅមិនរួច ដោយសារតែបរិស្ថាន នៅក្នុងការិយាល័យ។ ចាស់ៗខ្លះគេស៊ីលុយ។ អ៊ីចឹង បើយើងមិនស៊ីលុយ គឺនៅជាមួយគេមិនចុះ។ ដូចនេះ ស៊ីលុយ បន្លំលុយពន្ធ បន្លំចាយលុយរបស់រដ្ឋ។ ដល់អ៊ីចឹង ខ្ញុំក៏សារភាព ជួនកាលចំណាយនឹងមិនត្រូវខ្ទង់ទេ តែយើងធ្វើដើម្បី អោយវាត្រូវខ្ទង់។

**អ្នកនាំសារៈ** តើការធ្វើជាគំរូមានសារៈសំខាន់យ៉ាងណា?

**លោកបណ្ឌិតៈ** យើងត្រូវមានឧត្តមគតិជាគោល។ ក្មេងៗចង់បានគំរូពីយើង។ អ្នកខ្លះយកកីឡាករជាគំរូរបស់ខ្លួន។ ដូច្នេះ ឪពុកម្តាយគឺជាគំរូ ជាគ្រូរបស់កូនដែរ។ គ្រូត្រូវមានទំនាក់ទំនងស្គាល់សិស្សរបស់ខ្លួន។ បញ្ហាសព្វថ្ងៃ គឺក្នុងថ្នាក់មានសិស្សច្រើនពេក យើងស្គាល់មិនអស់ទេ។ ដោយសារប្រាក់ខែតិច ត្រូវរកលុយបន្ថែម មានបង្ខំក្មេងឱ្យរៀនគួរបន្ថែម និងលក់ឯកសារផ្សេងៗយកថ្លៃ។

វណ្ណា

Photo P.Rafaud

# “គឺអ្នកជាអ្នកដោះស្រាយបញ្ហានេះ!”

**អ្នកនាំសារ:** តើបងស្រីមកបង្រៀននៅសកលវិទ្យាល័យនេះរយ:ពេលប៉ុន្មានឆ្នាំហើយ? និងមានបទពិសោធន៍យ៉ាងដូចម្ដេចខ្លះ?

**បងស្រីល្វីស:** ខ្ញុំបង្រៀននៅទីនេះអស់រយ:ពេល ១៣ ឆ្នាំហើយ។ បទពិសោធន៍ដែលខ្ញុំមានជាមួយនិស្សិតឃើញថា ការអប់រំមិនទាន់ល្អនៅឡើយទេ។ ប៉ុន្តែ ខ្ញុំអាចនិយាយបានថា និស្សិតមានការរីកចំរើនច្រើន ជាងបណ្ដាឆ្នាំ ១៩៧៩-១៩៨៥។ ពេលនោះ គឺគ្មានឯកសារអ្វីទាំងអស់សំរាប់និស្សិត ពីព្រោះប្រទេសយើងទើបរួចផុតពីរបបប៉ុលពត។ ឥឡូវនេះ ដោយសារមានកិច្ចសហការពីរដ្ឋាភិបាលនៃប្រទេសផ្សេងៗដូចជា អាមេរិក បារាំង អូស្ត្រាលី អ៊ីតាលី ជាដើម នៅក្នុងការបណ្ដុះបណ្ដាលគ្រូបានធ្វើអោយមានការរីកចំរើនយ៉ាងខ្លាំង នៅតាមមហាវិទ្យាល័យមួយចំនួន។ កម្មវិធីភាសាអង់គ្លេសបច្ចុប្បន្នមានគុណភាពល្អ ដោយនិស្សិតទាំងអស់បានសិក្សា ៦ ឆមាសរឺសម្រាប់ឆ្នាំទី ១ ទី ២ និងទី ៣។ យើងមានកម្មវិធីធំ ប៉ុន្តែយើងមានសាស្ត្រាចារ្យតែ ៣០ នាក់ ដែលក្នុងនោះមានពាក់កណ្ដាលជាខ្មែរ។ ជារៀងរាល់ឆ្នាំ កំរិតបណ្ឌិតរបស់និស្សិតត្រូវបានធ្វើឱ្យល្អប្រសើរ។ តែទោះជាយ៉ាងណាក៏ដោយ ក៏មិនទាន់ដល់កំរិតអស្ចារ្យដែរ ពីព្រោះវាជាកំហុសរបស់សង្គមប្រវត្តិសាស្ត្រ។

**អ្នកនាំសារ:** តើចំនុចល្អនិងចំនុចខ្វះខាតនៅក្នុងប្រព័ន្ធអប់រំឥឡូវនេះមានអ្វីខ្លះ?

**បងស្រីល្វីស:** ចំនុចល្អគឺមានគ្រូរដ្ឋ និងគ្រូដែលបង្រៀននៅតាមមហាវិទ្យាល័យឯកជនមួយចំនួនបានមានការស្រាវជ្រាវច្រើន។ ប៉ុន្តែក៏មានគ្រូមួយចំនួន មិនសូវមានការចាប់អារម្មណ៍ចំពោះការបង្រៀន ដោយសារប្រាក់បៀវត្សតិច ហើយពួកគេធ្វើការនៅខាងក្រៅ។ ដូច្នេះ គ្មានពេលវេលាដើម្បីរៀបចំការត្រៀមបង្រៀនឱ្យបានត្រឹមត្រូវទេ។ បើនៅតាមជនបទ ទាំងគ្រូទាំងសិស្ស គឺក្រដូចគ្នា។ ដូច្នេះ តើយើងធ្វើយ៉ាងដូចម្ដេចទៅ? មានគ្រូខ្មែរតិចតួច បានបញ្ចប់ថ្នាក់អនុបណ្ឌិតពីបរទេស ហើយត្រឡប់មកបង្រៀននៅប្រទេសខ្មែរ ប៉ុន្តែបានរយ:មួយពេលខ្លី ហើយគេក៏ចាកចេញទៅវិញដោយរដ្ឋាភិបាលឱ្យប្រាក់បៀវត្សតិច។ លើសពីនេះ នៅមានវិបត្តិមួយទៀត គឺថានិស្សិតខ្មែរប្រហែល ៥០ ពាន់នាក់បានកំពុងរៀនសកលវិទ្យាល័យផ្នែកពាណិជ្ជកម្ម ដោយពួកគេស្រមៃថា នឹងរកការងារធ្វើបានស្រួល។ ប៉ុន្តែធាតុពិតក្នុងមួយឆ្នាំៗចំពោះផ្នែកនេះ និស្សិតអាចរកការងារបានធ្វើ មានចំនួនតែ ២០០ នាក់ប៉ុណ្ណោះ។

**អ្នកនាំសារ:** តើសកម្មភាពរបស់និស្សិតនៅទីនេះវិញយ៉ាងដូចម្ដេចដែរ បើប្រៀបធៀបនឹងនៅឯបរទេស?

**បងស្រីល្វីស:** ចំពោះនិស្សិតនៅទីនេះមានភាពរីកចំរើនច្រើន ជាពិសេសផ្នែកភាសា និងការស្រាវជ្រាវតាមបណ្ណាល័យ ដែលក្នុងនោះមាន ៦៥% ជាសៀវភៅភាសាអង់គ្លេសល្អៗ។ និស្សិតសព្វថ្ងៃ ការសិក្សារបស់ពួកគេ ពិតជាបានល្អប្រសើរ តែពិបាកប្រៀបធៀបទៅនឹងប្រទេសដទៃ ពីព្រោះយើងកំពុងធ្វើការអភិវឌ្ឍន៏។

**អ្នកនាំសារ:** តើបងស្រីយល់ថា នៅទីនេះមានសៀវភៅគ្រប់គ្រាន់សំរាប់និសិ្សតក្នុងការសិក្សារដែររឺទេ?

**បងស្រីល្វីស:** មានសៀវភៅមួយចំនួនបានបកប្រែជាភាសាខ្មែររួចហើយ ដូចជាលោកបូជាចារ្យអាស្លី បានធ្វើសៀវភៅមេរៀនប្រហែល ៦០ ក្បាលជាមួយគ្រូខ្មែរ។ ប៉ុន្តែ នៅមានមហាវិទ្យាល័យខ្លះ នៅមានការខ្វះខាតដូចជាផ្នែកវិទ្យាសាស្ត្រដែលពុំទាន់មានសាស្ត្រាចារ្យថ្នាក់បណ្ឌិត



D.r Luise Ahrens

Photo P.Rafaud

ទទួលខុសត្រូវនៅឡើយ។ ខ្ញុំមិនសូវយល់ស្របជាមួយរដ្ឋាភិបាលដែរ ដែលឱ្យគេធ្វើការបកប្រែសៀវភៅ ដោយយោងទៅតាមបទពិសោធន៍ក្នុងការបង្រៀន រឺដកស្រង់ចេញពីសៀវភៅនេះចេញពីសៀវភៅនោះ ដើម្បីសរសេរជាសៀវភៅថ្មី។ ម្យ៉ាងវិញទៀតសព្វថ្ងៃនេះ មូលនិធិអេស៊ីលីដា បានបង្កើតមជ្ឈមណ្ឌលព័ត៌មានសហគមន៍នៅតាមបណ្តាខេត្តនីមួយៗ ដែលអាចឱ្យនិស្សិតមានឱកាសអាន និងរៀនបានទោះជាមិនសូវច្រើនក្តី ប៉ុន្តែ វាក៏ជាការចាប់ផ្តើមដែរ។ បើនិយាយអំពីសិក្សាធិការនោះគួរតែភ្ជាប់វាទៅនឹងសេដ្ឋកិច្ចខ្នាតធំផងដែរ។ ហើយបើគិតអំពីការអប់រំសិក្សា គួរតែគិតថាការអប់រំសិក្សាពីអ្វី និងសំរាប់អ្វី? យើងគួរតែអប់រំមនុស្សឱ្យចេះអាន យល់អំពីបញ្ហាផ្សេងៗក្នុងជីវិត និងអំពីដំណើរវិវឌ្ឍន៍នៃប្រវត្តិសាស្ត្រជាតិ និងពិភពលោក ដើម្បីឱ្យគេមានបទពិសោធន៍ក្នុងការអភិវឌ្ឍន៍ប្រទេសរបស់ខ្លួន។

**អ្នកនាំសារៈ** ដូច្នេះ តើយើងធ្វើយ៉ាងដូចម្តេចទើបអាចដោះស្រាយបញ្ហានេបាន?

**បងស្រីល្វីសៈ** គឺអ្នកជាអ្នកដោះស្រាយបញ្ហានេះ! ពីព្រោះអ្នកជាយុវជន និងជានិស្សិតរបស់ប្រទេសជាតិ ហើយដែលត្រូវបង្កើនសមត្ថភាពខ្លួន ដោយចាប់ផ្តើមរិះគិតសរសេរ និងធ្វើរឺដេរអ្វីដែលទាក់ទិននឹងបញ្ហានេះ។ អ្នកត្រូវសាកល្បងគិតថា តើត្រូវធ្វើដូចម្តេច ដើម្បីអភិវឌ្ឍប្រទេសកម្ពុជា។ បញ្ហានេះ អ្នករាល់គ្នាត្រូវតែនិយាយមិនមែនជនបរទេសឡើយ។ ខ្ញុំអាចធ្វើអ្វីបានតែបន្តិចបន្តួច។ ខ្ញុំអាចជួយត្រួតពិនិត្យថា តើអង្គការក្រៅរដ្ឋាភិបាលយកប្រាក់ទៅធ្វើអ្វីខ្លះ ក្នុងវិស័យអប់រំសិក្សា។ ប៉ុន្តែ ខ្ញុំមិនអាចនិយាយឱ្យដូចជនកម្ពុជាបានឡើយ។

ក.ធារី


Photo D.R

## ការសិក្សាមិនទាន់មានលក្ខណៈស្តង់ដា

តាមសំដីលោក Rene Ayala (Master Program Coordinator) មកពីប្រទេសបូលីវៀ បាននិយាយថា “ចំពោះការសិក្សានៅប្រទេសកម្ពុជា គឺមិនទាន់មានលក្ខណៈស្តង់ដានៅឡើយទេ ដោយសារតែប្រទេសនេះបានឆ្លងកាត់នូវសង្គ្រាម និងនិស្សិតមានការខ្វះខាតខាងភាសាបរទេស”។ លោកបានបន្តដោយសុទិដ្ឋិនិយមទៀតថា “ប្រហែលជា ១០-១៥ ឆ្នាំ ទៀតប្រព័ន្ធអប់រំនៅកម្ពុជានឹងរីកចំរើនទៅមុខ ទោះបីជាស្ថានភាពរបស់សាលា និងនយោបាយនៅក្នុងប្រទេសខ្មែរមានលក្ខណៈដូចសព្វថ្ងៃក៏ដោយ ពីព្រោះនិស្សិតភាគច្រើន មានលទ្ធភាពទៅបន្តការសិក្សានៅបរទេសហើយវិលមកដើម្បីជួយប្រទេសរបស់ខ្លួនវិញ”។ លោកបានបន្តទៀតថា “និស្សិតខ្មែរយើងនូវមានបញ្ហាមួយ គឺពួកគេឥតមានគំនិតក្នុងការរិះគន់ ទៅលើអត្ថបទដែលពួកគេបានអាននោះទេ ពួកគេតែងតែគិតថា ការបង្រៀនរបស់គ្រូបរទេសទាំងអស់សុទ្ធតែត្រឹមត្រូវ ប៉ុន្តែ មិនបានត្រិះរិះពិចារណាថា វាពិតជាត្រឹមត្រូវនោះឡើយ”។ ដូច្នេះ ក្នុងនាមយើងជាខ្មែរ ចាំបាច់ត្រូវតែបង្កើននូវគំនិតក្នុងការរិះគន់ស្ថាបនា ទោះបីជាវាលំបាកយ៉ាងណាក៏ដោយ យើងត្រូវតែព្យាយាមទៀត នោះកិច្ចការរបស់យើងនឹងល្អប្រសើរ។

យើងត្រូវតែអានសៀវភៅបើយើងចង់អាន ពីព្រោះក្នុងថ្នាក់យើងទទួលចំណេះពីលោកគ្រូអ្នកគ្រូបានតែ ១០-២០% ប៉ុណ្ណោះ ហើយ ៨០% ទៀត គឺរៀនដោយខ្លួនឯង ដូចនេះ យើងត្រូវចំណាយពេលលើការអានសៀវភៅ។ ក.ធារី


Photo D.R

## ការអប់រំនៅក្នុងប្រទេសកំពុងអភិវឌ្ឍ

លោកបណ្ឌិត Bruno Multoni មកពីសាកលវិទ្យាល័យ Trieste ផ្នែកសង្គមវិទ្យានៃប្រទេសអ៊ីតាលី បច្ចុប្បន្ននេះគាត់ជាសាស្ត្រាចារ្យនៅសកលវិទ្យាល័យភូមិន្ទភ្នំពេញ ផ្នែកសង្គមវិទ្យានិងនរៈវិទ្យា។ លោកបានមានប្រសាសន៍ថា “ការអប់រំនៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្នមានលក្ខណៈល្អប្រសើរ និងកំពុងអភិវឌ្ឍយ៉ាងខ្លាំង ដោយនិស្សិតភាគច្រើនបាននឹងកំពុងបន្តការសិក្សានៅបរទេស។ ម្យ៉ាងទៀត ទៅថ្ងៃក្រោយដែលបង្រៀននៅមហាវិទ្យាល័យ យ៉ាងហោចណាស់ក៏មានកំរិតត្រឹមថ្នាក់អនុបណ្ឌិតដែរ”។ ប៉ុន្តែ គាត់ក៏បានផ្តោតអារម្មណ៍ទៅលើនិស្សិតមួយចំនួន ដែលពួកគេមិនទាន់ចេះពីវិធីសាស្ត្រនៃការអានសៀវភៅផងដែរ។

ចំពោះប្រទេសដែលមានការរីកចំរើនលើប្រព័ន្ធអប់រំ ឯកសារផ្សេងៗមានជាភាសាជាតិរបស់គេផ្ទាល់។ គាត់គិតថា ប្រព័ន្ធអប់រំនឹងរីកចំរើនតាមរយៈសហប្រតិបត្តិការជាមួយបរទេស និងការស្រាវជ្រាវឯកសារតាមប្រព័ន្ធអិនធឺណែតជាដើម។

ជាចុងបញ្ចប់ គាត់បានមានមតិលើកទឹកចិត្តថា “និស្សិតភាគច្រើនគឺនៅខ្វះភាពក្លាហានក្នុងការសាកល្បង ដូចជាការប្រលង ប៉ុន្តែបើយើងមិនចាប់ផ្តើមនោះ យើងមិនដឹងថា មានអ្វីកើតឡើងនោះទេ ថ្វីបើយើងធ្វើមិនជាប់ថ្ងៃនេះ យើងអាច នឹងព្យាយាមម្តងទៀត កុំបោះបង់ចោលនូវការតស៊ូ។ ក.ធារី

# ដោយសារគ្រួសារថ្មី ដៃជើងគឺជាភាសា



Photo Krousar Thmey

សកម្មភាពសិក្សា ក្មេងពិការភ្នែក



កាលមួយនោះ មានក្មេងប្រុសម្នាក់ដែលវិលត្រឡប់មកពីជំរំជនភៀសខ្លួន នៅឆ្នាំ ១៩៩៣ មានបំណងចង់ទៅសាលារៀន។ ប៉ុន្តែ ភ្នែករបស់គេពិការ។ សំណាងល្អ! គេមានអារម្មណ៍ថា នៅតាមដងផ្លូវមានបុរសម្នាក់ ដែលដូចជាមានមន្តអាគម បានសន្យាថា នឹងបំពេញក្តីបំណងរបស់គេ។ ១០ ឆ្នាំក្រោយមក គេក៏បានក្លាយក្លាយខ្លួនទៅជាគ្រូតន្ត្រី។ វណ្ណា បានអះអាងថា: "ខ្ញុំគ្រាន់តែ ជាក្មេងដែលមានប្រភពចេញពីសាលារៀនដំបូង គេសំរាប់ក្មេងៗពិការភ្នែកក្នុងប្រទេសប៉ុណ្ណោះ។ ខ្ញុំបានរៀនសូត្រអស់រយៈពេល ៧ ឆ្នាំ។ គឺគួរជាទីចាប់អារម្មណ៍ណាស់ដែលបានសិក្សាដូច ក្មេងៗដទៃ"។

**Corinne Javary** អ្នកផ្តល់ព័ត៌មាននៃសមាគមគ្រួសារថ្មី បានគូសបញ្ជាក់ថា: "ពិការភាពក្នុងទីកន្លែងនៃពិភពលោកនេះ ត្រូវបានចាត់ទុកជាលទ្ធផលនៃសកម្មភាពមិនល្អ ដែលត្រូវបានគេប្រព្រឹត្តឡើងកាលពីអតីតជាតិ"។ "ឪពុកម្តាយមានការខ្មាសអៀន និងមានទំនោរលាក់កូនៗរបស់ខ្លួន។ ជារឿយៗ ពួកគេនឹកឃើញថាក្មេងមានភាពយឺតយ៉ាវខាងសតិបញ្ញា និងមិនដឹងថា ក្មេងទាំងនេះអាចរៀនសូត្រ និងអាចមានសមត្ថភាពខាងការរិះគិតនោះទេ។ ដោយសារហេតុនេះ ក្មេងៗទាំងនោះដូចជាត្រូវបានគេដាក់ឱ្យនៅដាច់ដោយឡែក ឱ្យធ្វើកិច្ចការផ្ទះ ឬក៏ត្រូវបោះបង់ចោលទៀតផង"។

នៅក្នុងឆ្នាំ ១៩៩៤ មិនមានអ្វីសោះសំរាប់ការអប់រំក្មេងៗពិការ។ ក្រោមការជំរុញពីលោកនាយក **Benoît Duchateau-Armijon** សមាគមក៏បានសំរេចចិត្តអភិវឌ្ឍកម្មវិធីមួយសំរាប់ការអប់រំក្មេងៗថ្លង់ និងពិការភ្នែក។ ក្រុមការងារមួយត្រូវបានបង្កើតឡើង ដើម្បីផលិតសំភារៈចាំបាច់សំរាប់ការអប់រំជាពិសេសដល់ក្មេងៗ បង្កើតលេខកូដ ប្រែ ខ្មែរ និងសំរបសំរួលមកជាភាសាខ្មែរនូវភាសាសញ្ញាអាមេរិកកាំង ដោយហេតុថា មុននឹងបើកឱ្យប្រើប្រាស់សាលារៀន ពិសេសដំបូងសំរាប់ជនពិការភ្នែក នៅច្បារអំពៅក្បែរទីក្រុងភ្នំពេញ យើងត្រូវមាន ឧបករណ៍គរុកោសល្យសិន។

**Corinne Javary** ពន្យល់ថា: "ក្មេងៗសិក្សាតាមកម្មវិធីអប់រំជាតិ ពីព្រោះយើងបានបកប្រែវាដោយមានការអនុញ្ញាតពីក្រសួងអប់រំ។ គឺចាប់ពីថ្នាក់ទី ៣ ឡើងសំរាប់អ្នកពិការភ្នែក និងចាប់ពីថ្នាក់ទី ៥ ឡើងសំរាប់អ្នកថ្លង់។ ក្មេងៗត្រូវឱ្យទៅរៀននៅសាលារដ្ឋមួយពេលក្នុងមួយថ្ងៃ។ កន្លះថ្ងៃទៀតនៅអង្គការគ្រួសារថ្មី ពួកគេទទួលនូវវគ្គបណ្តុះបណ្តាលជំនួយ និងការសិក្សាពិសេសសំរាប់ភាពពិការរបស់ពួកគេ តួយ៉ាងតន្ត្រីសំរាប់អ្នកពិការភ្នែក របាំសំរាប់អ្នកថ្លង់ និងការរៀនភាសាអង់គ្លេសដោយ មានកម្មវិធីនៃការបញ្ចេញសំលេង ដែលបានសំរបសំរួល"។

កុមារថ្លង់និងពិការភ្នែកប្រហែលពី ១០០០០ ទៅ ២០០០០ នាក់ មាននៅប្រទេសកម្ពុជា។ ដើម្បីឱ្យកុមារទាំងនេះទៅសាលារៀន ឱ្យបានកាន់តែច្រើន អង្គការបានអភិវឌ្ឍយ៉ាងទូលំទូលាយកម្មវិធីនេះតាំងពីឆ្នាំ ២០០១។ "កាលណាយើងអាចប្រមូលផ្តុំកុមារថ្លង់ និងពិការភ្នែកបាន ១០ នាក់ នៅក្នុងស្រុកមួយ គេអនុញ្ញាតិឱ្យយើងបង្កើត "ថ្នាក់រួមបញ្ចូល" មួយក្នុងសាលារដ្ឋ។ នេះគឺជាថ្នាក់យ៉ាងពិសេសនៅក្នុងសាលារដ្ឋ។ បន្ទាប់មកអាជ្ញាធរប្រគល់ឱ្យយើងនូវអគារមួយ ហើយយើងមានគ្រូម្នាក់ដែលយើងជាអ្នកបណ្តុះបណ្តាលផ្ទាល់។ ចំណែក អង្គការក្រៅរដ្ឋាភិបាលជាអ្នកផ្គត់ផ្គង់សំភារៈគរុកោសល្យ។ កម្មវិធីសិក្សានាពេលបច្ចុប្បន្ន អាចធ្វើឱ្យកុមារសំគាល់ផ្លូវដើរបាន។ នេះក៏អាចធ្វើឱ្យឪពុកម្តាយសិស្សមានភាពជិតដិត និងពួកគាត់ថែមទាំងអាចរក្សាបាននូវទំនាក់ទំនងប្រចាំថ្ងៃជាមួយនឹងកុមារ។ អ៊ីចឹង ឪពុកម្តាយសិស្ស អាចត្រួតពិនិត្យការសិក្សារបស់កូនគាត់។

ដើម្បីបានជោគជ័យលើកម្មវិធីនេះ ការចូលរួមរបស់រដ្ឋាភិបាល គឺមានសារៈសំខាន់ណាស់ពីព្រោះ "អង្គការមិនចំណាយលុយ ១០០% ទេ"។

# រោងពុម្ពអក្សរប្រែនៅកម្ពុជា

១០ ឆ្នាំបន្ទាប់ពីការបង្កើតនូវសាលារៀនដំបូង អង្គការក្រៅរដ្ឋាភិបាល គ្រួសារថ្មី គឺជាអង្គការតែមួយគត់ ដែលមានសំណើរឱ្យមានការអប់រំជាក់លាក់ សំរាប់កុមារពិការភ្នែក និងថ្លង់។ ដោយមានក្តីប៉ងប្រាថ្នា ប្រមូលផ្តុំនូវរាល់សកម្មភាពរបស់ខ្លួន លើការអប់រំនៅកំរិតបឋមសិក្សា និងមុនបឋមសិក្សា អង្គការបានធ្វើកិច្ចសហការជាមួយរដ្ឋាភិបាល និងសមាគមឯកទេសផ្សេងៗ ក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីផ្តល់លទ្ធភាពឱ្យកុមារថ្លង់ចំនួន ៦២៣ នាក់ និងពិការភ្នែកចំនួន ១៥៨ នាក់ ព្រមជាមួយនឹងសិស្សប្អូនជំនាន់ក្រោយរបស់ពួកគេបានបន្តការរៀនសូត្រទៅថ្ងៃខាងមុខទៀត។

នៅខែតុលាឆ្នាំ ២០០៤ ដើម្បីឆ្លើយតបទៅនឹងបញ្ហាដោយឡែករបស់កុមារថ្លង់ អង្គការនឹងបើកសាលាមត្តេយ្យសិក្សាមួយឱ្យដល់ពួកគេ។ Corinne Javary អះអាងថា: "ស្វែងរកក្មេងមានការលំបាកណាស់។ ឪពុកម្តាយតែងតែប្រឆាំងជំទាស់"។ "ឪពុកម្តាយ ក៏គួរចូលរួម និងរៀនភាសាសញ្ញាផងដែរ"។ យុវជន វណ្ណា ដែលចេញពីជំរំ បានមានសំណាងកែប្រែវាសនារបស់ខ្លួនដោយ ទទួលបានសិទ្ធសំរាប់ការសិក្សា។ តើមានប៉ុន្មាននាក់? ប្រហែលជា ១០% នៃក្មេងៗពិការនៅអាស៊ីបានចូលរៀន។ ក្នុងនោះមានវណ្ណា ដែលបានស្រែកឡើងយ៉ាងខ្លាំងថា: "ខ្ញុំស្រលាញ់ជីវិតថ្មីនេះ"។

(023 366 184) P R

អក្សរប្រែជាប្រភេទអក្សរសំរាប់បង្រៀនជនពិការភ្នែក ដើម្បីចេះអាន និងសរសេរ។





Photos P.Rafaud



របៀបអានអក្សរនេះ គឺអានដោយប្រើដៃស្ទាំ និងសរសេរដោយប្រើឧបករណ៏ "បន្ទះស្លែឡាស់" ចុចជាចំនុចអក្សរប្រែនេះ។ "សំរាប់ការអប់រំ និងបង្កលក្ខណៈងាយស្រួលដល់ជនពិការភ្នែកទាំងអស់ ក្នុងការរៀនអាន ឬសរសេរ អង្គការគ្រួសារថ្មី បានរៀបចំបោះពុម្ពសៀវភៅគ្រប់កំរិតចាប់ពីបឋមសិក្សាដល់មធ្យមសិក្សា ដោយស្របតាមក្រសួងអប់រំ។ រោងពុម្ព ២កន្លែង ផ្សេងគ្នា គឺនៅច្បារអំពៅបោះពុម្ពផ្នែកអក្សរសាស្ត្រ និងសង្គមសាស្ត្រ នឹងនៅចាត់ដំបងបោះពុម្ពផ្នែកគណិតវិទ្យា"។ នេះជាប្រសាសន៏លោកស្រី នាង ផល្លា អ្នកសំរបសំរួលកម្មវិធីអប់រំកុមារពិការភ្នែក និងកុមារ គ ថ្លង់ ច្បារអំពៅ។ ចំពោះការបោះពុម្ព លោកស្រីបានបញ្ជាក់ទាំងញញឹមថា "ដោយធ្វើការចម្លងពីសៀវភៅរបស់ក្រសួងអប់រំទាំងស្រុង ដោយមានគណៈកម្មការត្រួតពិនិត្យចេញពីអង្គការផ្ទាស់"។ លោកស្រីក៏បានពន្យល់បន្ថែមដែរ អំពីក្រុមសាស្ត្រាចារស្រាវជ្រាវដែលមានបទពិសោធន៏យូរឆ្នាំលើសញ្ញាផ្សេងៗ ផ្នែកគណិតវិទ្យាជាអក្សរប្រែ។ ចំណែកបច្ចេកទេសនៃការបោះពុម្ព លោក គង់ ប៊ុនធី បានឱ្យដឹងថា "មានការឧបត្ថមពីសាលា Over Brock School for the Blind នៅសហរដ្ឋអាមេរិក ដូចជាកម្មវិធីកំព្យូទ័រជាអក្សរប្រែជាដើម"។

វណ្ណា



ខ្ញុំ / មានអាយុ / ៣១ / ឆ្នាំ

Photo P.Rafaud

# បញ្ជីរាយមុខម្ហូប៖ គុណភាព!

នៅពេលឈានចូលដល់ក្នុងសាលា Paul Dubrulle អនាគតសិស្សទាំងឡាយបានភ្ញាក់ផ្អើល។ សាលាពួកគេប្រៀបបាននឹងសណ្ឋាគារមួយ។ មានកន្លែងទទួលភ្ញៀវមាន ភោជនីយដ្ឋាន ១ សំរាប់ភ្ញៀវ ៦០ នាក់ មានបានិងបន្ទប់ប្រណីតៗដែលរង់ចាំទទួលពួកគេ។ Béatrice Baranger ជានាយិកាសាលាសណ្ឋាគារ និងទេសចរណ៍ Paul Dubrulle នៅសៀមរាបបញ្ជាក់ថា: “នេះគឺជាសាលាអនុវត្តន៍ការងារដែលអាចឱ្យសិស្សធ្វើការបានជាក់ស្តែង ក្រោយពីរៀនលើផ្នែកទ្រឹស្តី”។

ដោយចាប់ដំនើរការនៅឆ្នាំ២០០២ ក្រោមការផ្តួចផ្តើមរបស់លោក Paul Dubrulle សហស្ថាបនិកក្រុមហ៊ុនសណ្ឋាគារ Accor សាលានេះគឺជាមណ្ឌលដែលបង្រៀនជំនាញសណ្ឋាគារនិងទេសចរណ៍ ដូចជា វិធីធ្វើម្ហូប របៀបទទួលភ្ញៀវ ការរៀបចំបន្ទប់ និងដំនើរ ទេសចរណ៍។ ដោយឆ្លើយតបយ៉ាងមុះមុតទៅនឹងកង្វះខាតបុគ្គលិក ដែលមានគុណសម្បត្តិនៅកម្ពុជា សាលាបំពេញបាននូវគោលបំណងរបស់ខ្លួន តាំងពីឆ្នាំទី១។ សិស្ស ១២២ នាក់ ដែលបានចុះឈ្មោះ អាចរកការងារធ្វើបាន។ លោក ញឹម ដារិទ្ធិ ដែលជានាយករងបានពោលថា: “ប្រធានសណ្ឋាគារនានានៅក្នុងក្រុងអង្គរ បានដឹងអំពីគុណភាពនៃការការបណ្តុះបណ្តាលរបស់យើង។ តាំងពីមុនពេលចែកសញ្ញាបត្រ ពួកគេមកជ្រើសរើសសិស្សរបស់យើង”។


Photos EHT

អនុវត្តជាក់ស្តែងលើរបៀបទទួលភ្ញៀវ

លោកនាយករងចង់បញ្ជាក់ថា: “នេះមិនមែនជាសាលាសំរាប់តែអ្នកមានទេ”។ “ប្រជាកសិករចុះឈ្មោះកូនពួកគាត់ដោយដឹងថា នឹងមានការអប់រំមួយ ដែលអាចឱ្យកូនរបស់គាត់រកការងារបានធ្វើ។ នៅទីនេះ សិស្សមិនទិញសញ្ញាប័ត្រទេ”។ លោក ញឹម ដារិទ្ធ និយាយទៀតថា: “យើងម៉ឺងម៉ាត់ណាស់ចំពោះវិន័យ ដើម្បីសំដៅយកគុណភាព។ នេះជាបញ្ហាសំរាប់សិស្សខ្លះ។ ប៉ុន្តែពួកគេអាចជំនះបាន។ សិស្សចំណានៗរបស់យើង ជាក្មេងដើរប្រមូលសំរាម ដែលអង្គការដើម្បីភាពញញឹមនៃកុមារបានផ្ញើមក។ យើងត្រូវតែផ្តល់អាហារូបករណ៍ឱ្យពួកគេ។ គុណភាពនេះ ក៏ស្ថិតនៅក្នុងរបៀបនៃការអប់រំផងដែរ។ មុខវិជ្ជាត្រូវបង្រៀនដោយគ្រូពីរនាក់។ ម្នាក់ជាជនជាតិអឺរ៉ុប ម្នាក់ទៀតជាខ្មែរ។ ដោយទទួលបទពិសោធន៍ពីសាលាបារាំង ៣ កន្លែងដែលបង្រៀនមុខវិជ្ជាសណ្ឋាគារ សាលាបានទទួលអ្នកជំនាញមកពិនិត្យមើលគុណភាពនៃការអប់រំ និងកម្មវិធីសិក្សា។

ប៉ុន្តែ ការអប់រំមិនសំដៅតែលើមុខអាជីពប៉ុណ្ណោះទេ។ សិស្សទាំងឡាយត្រូវបានធ្វើឱ្យមានទំនួលខុសត្រូវក្នុងការរស់នៅផងដែរ។ សំរាប់សិស្សដែលធ្វើដំនើរដោយម៉ូតូ សាលាឱ្យពួកគេពាក់មួកការពារក្បាល។ គ្មានកំទេចកំទីក្រដាសនៅនឹងដីទេ ទោះនៅខាងក្រៅសាលាក្តី ឬខាងក្នុងសាលាក្តី។ ការប្រមូលសំរាមត្រូវធ្វើឡើងជាប្រចាំថ្ងៃ។ សន្និសីទនានាត្រូវបានធ្វើឡើង ដើម្បីធ្វើឱ្យសិស្សចាប់អារម្មណ៍ទៅនឹងបញ្ហាសង្គម។ “គេព្យាយាមអប់រំឱ្យមានគំនិតនៃការស្រលាញ់មុខរបរ ស្រលាញ់ចំណេះចេះធ្វើ និងផ្តល់ឱ្យអាជីពមួយឱ្យយុវជនដែលធ្វើឱ្យពួកគេមានភាពស្រស់ស្រាយសំរាប់ការអភិវឌ្ឍន៍យូរអង្វែង”។



ការហ្វឹកហាត់ធ្វើម្ហូបនៅនឹងកន្លែង

សាលា Paul Dubrulle ខុសពីគេដោយសារវិធីសាស្ត្ររបស់ខ្លួនព្រមទាំងឧបនិស្ស័យអន្តរជាតិពិតប្រាកដ ជាពិសេសដោយភាពសមស្ទួនរបស់ខ្លួន ជាមួយនឹងផ្នែកសេដ្ឋកិច្ច ដែលកំពុងរីកចំរើន។ ចាប់ប្រភពជាមណ្ឌលតំបន់ កិត្តិសព្ទនៃវិជ្ជាជីវៈនិយមបានឆ្លងកាត់ហួសព្រំដែនខេត្តទៅទៀត។ តើកិត្តិសព្ទដែលអាងលើគុណភាព និងភាពចាំបាច់នៃការអបរំនេះអាចផ្តួលរលំនូវឧបសគ្គ និងជំរុញឪពុកម្តាយទាំងឡាយចុះឈ្មោះកូនស្រីខ្លួនឱ្យចូលរៀនបានច្រើនថែមទៀតដែរឬទេ? មានសិស្សតែ ២៥ % ប៉ុណ្ណោះដែលជាយុវតី។ លោក ញឹម ដារិទ្ធិ បញ្ជាក់ថា: “យើងអាចនៅជាខ្មែរនៅពេលបើក ចិត្តទូលាយទៅកាន់ពិភពអន្តរជាតិ។ យើងត្រូវតែរកឱ្យឃើញផ្លូវកណ្តាល។ អ្វីដែលប្រសើរបំផុតសំរាប់កម្ពុជា គឺការរៀនសូត្រអំពីប្រទេសបារាំងក៏ដូចជាអន្តរជាតិទាំងមូល”។

(063 963 672)

P R

# បច្ចេកទេសកសិកម្មជាអាទិភាពចម្បង

មនុស្សលោកថ្មី គឺជាឈ្មោះរបស់អង្គការក្រៅរដ្ឋាភិបាលមួយ ដែលជួយរួមចំណែកលើស្នួយការអប់រំក្រៅប្រព័ន្ធនិងផ្នែកកសិកម្ម។ ដោយមានទីតាំងស្ថិតនៅភាគខាងត្បូងរាជធានីភ្នំពេញ តាមដងផ្លូវជាតិលេខ ២ ក្នុងភូមិសាស្ត្រស្រុក កណ្តាលស្ទឹង ខេត្តកណ្តាល មណ្ឌលអភិវឌ្ឍន៍ ឃុំអំពៅព្រៃ ដែលជាទីតាំងកណ្តាលមួយរបស់អង្គការ បានអនុវត្តយ៉ាងសកម្មនូវកម្មវិធីផ្សេងៗរបស់ខ្លួន មានជាអាទិ៍ កម្មវិធីកសិកម្មដែលជាកម្មវិធីមួយជួយប្រជាជនភាគច្រើនដែលជាកសិករ។

ក្នុងទិសដៅបង្កើនទិន្នផលកសិកម្ម អង្គការបានធ្វើការអប់រំនិងផ្សព្វផ្សាយចំណេះដឹងខាងកសិកម្មជូនដល់ប្រជាកសិករ ទាំងផ្នែកទ្រឹស្តីព្រមទាំងផ្សារភ្ជាប់ទៅនឹងការអនុវត្តន៍ការងារជាក់ស្តែង។ អង្គការបានបង្រៀនឱ្យចេះជ្រើសរើសពូជ ចេះថែទាំស្រូវ និងបង្កើតសាលារៀនស្រែកសិករ ដែលជាទីស្រែពិសោធន៍ការងារដាំដុះដំណាំស្រូវ។ ចំណែកការចិញ្ចឹមសត្វ ធនាគារ ១ ត្រូវបានបង្កើតឡើង ដើម្បីផ្តល់ឥណទានឱ្យកសិករ ក្នុងការទិញជ្រូកមកចិញ្ចឹម និងថែមទាំងមានការធ្វើវ៉ាក់សាំង សំរាប់ការពារជំងឺឆ្លងរបស់គោផងដែរ។ មិនត្រឹមតែប៉ុណ្ណោះ ចំពោះផ្នែកដំណាំបន្លែ អង្គការបានជួយបង្ហាត់បង្រៀននិងជួយអភិវឌ្ឍខាងសំភារៈដាំបន្លែ ចែកគ្រាប់ពូជ និងផ្តល់បច្ចេកទេសខាងការដាំដុះ។ ចំពោះគ្រប់សកម្មភាពបណ្តុះបណ្តាលទាំងអស់ អង្គការបានជំរុញឱ្យមានកិច្ចការពារបរិស្ថាន ដោយបានបង្ហាញពីផលលំបាកក្នុងការប្រើប្រាស់ថ្នាំពុលនិងឱ្យកសិករចេះប្រើជីកំប៉ុស្ត ជីលាមកសត្វជាដើម ដើម្បីលើកកំពស់គុណភាពដី។

រាល់គ្រប់កម្មវិធីរបស់អង្គការ ត្រូវបានទទួលការចាប់អារម្មណ៍ពីប្រជាកសិករយ៉ាងខ្លាំង ជាពិសេសការដាំដុះដំណាំស្រូវ ដែលរហូតមកទល់ពេលនេះ កសិករខ្លះអាចធ្វើស្រែពី ២ ទៅ ៣ ដងក្នុងមួយឆ្នាំ ដោយមានប្រព័ន្ធទឹកស្រោចស្រពគ្រប់គ្រាន់។ ទោះជាយ៉ាងនេះក្តី បញ្ហាដែលត្រូវប្រឈមមុខដោះស្រាយ នៅមានច្រើននៅឡើយ តួយ៉ាងផលិតផលដែលធ្វើបាន គឺត្រូវដឹកនាំយកទៅលក់នៅឯទីផ្សារតែម្តង ដោយមិនទាន់មានគំរោងកែច្នៃ ឬវេចខ្ចប់ឱ្យបានល្អ ដើម្បីឱ្យលក់បានតំលៃខ្ពស់នៅឡើយទេ។ ម្យ៉ាងវិញទៀត អង្គការមិនទាន់មានគំរោងគិតគូររឿងទីផ្សាសំរាប់លក់ផលិតផលដែរ ពោលគឺប្រជាកសិករខ្លួនឯងផ្ទាល់ ដែលជាអ្នកចាត់ចែងលក់ផលកសិកម្មដែលធ្វើបាន ដោយហេតុនេះហើយ ទើបពេលខ្លះផលិតផលកសិកម្មត្រូវឈ្មួញវាយបង្អាប់តំលៃចុះទាបយ៉ាងខ្លាំង។

តាមប្រសាសន៍របស់លោក ញឹក ចំរើន ដែលជាអ្នកសំរបសំរួលកម្មវិធីកសិកម្មនៃអង្គការ បានឱ្យដឹងថា: “ការបណ្តុះបណ្តាលបច្ចេកទេសមានសារៈសំខាន់ណាស់ ដើម្បីបង្កើនទិន្នផលផលិតផលកសិកម្មរបស់ប្រជាកសិករ ដែលនេះអាចធ្វើឱ្យពួកគាត់ទទួលបាននូវអាហារូបត្ថម្ភបំប៉នសុខភាពបន្ថែម ក៏ដូចជាអាចលក់យកកំរៃដើម្បីលើកកំពស់កំរិតជីវភាពរស់នៅផងដែរ”។ គាត់ក៏បានបន្តដោយសង្កត់ធ្ងន់ថា: “សំរាប់យុវជនការអប់រំស្តីអំពីកសិកម្ម ធ្វើឱ្យពួកគេអាចចិញ្ចឹមជីវិតបានគ្រប់គ្រាន់ ដោយមិនបាច់ដើរចេញទៅរកស៊ីឆ្ងាយ ចាកចោលភូមិស្រុក ពីព្រោះ គឺពួកគេនេះហើយដែលជាជំហររបស់គ្រួសារ នៅពេលដែលឪពុកម្តាយរបស់ខ្លួនឈានចូលដល់វ័យចាស់ជរា”។ **(023 882 304)** សំ ភី

## សាលាជាតិកសិកម្មព្រែកលៀប

ក.ព.លស្ថិតតាមដងផ្លូវជាតិលេខ ៦ A មានបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្ររងរយៈពេល ២ ឆ្នាំ និងកំរិតបរិញ្ញាបត្រវិទ្យាសាស្ត្ររយៈពេល ៤ ឆ្នាំ នូវមុខជំនាញវិទ្យាសាស្ត្រក្សេត្រសាស្ត្រវិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ គ្រប់គ្រងធនធានជលផល និងវារីវប្បកម្មគ្រប់គ្រងកសិកម្មរុក្ខកម្ម ផ្សព្វផ្សាយ និងអភិវឌ្ឍន៍ជនបទកសិពាណិជ្ជកម្ម-សេដ្ឋកិច្ច សាកវប្បកម្ម និងបច្ចេកវិទ្យាម្ហូបអាហារ។ ការសិក្សាមានទាំងអាហារូបករណ៍និងបង់ថ្លៃ។

សំ ភី

ទិន្នផល : ៨តោនក្នុងមួយហិកតា ក្រោយការបណ្តុះបណ្តាល។ មនុស្សលោកថ្មី



Photo P.Rafaud

# អគារសិក្សារថ្មី ត្រូវបានបើកឱ្យប្រើប្រាស់

ការចូលរួមអភិវឌ្ឍវិស័យអប់រំជាការសំខាន់ណាស់ សំរាប់ជួយស្តារប្រទេសជាតិយើង។ អគារសិក្សា ១ ខ្នង ជាអំណោយរបស់អង្គការដុនបូស្កូកម្ពុជា ផ្តល់ជូនប្រជាជនភូមិវត្តចំប៉ា ស្រុកកៀនស្វាយ ខេត្តកណ្តាល ត្រូវបានសម្ពោធឱ្យប្រើប្រាស់ ក្រោមអធិបតីភាពរបស់លោកអភិបាល អេមីល ដេតម្ប និងលោកឪពុក លេអូ តំណាងអង្គការដុនបូស្កូ និងមានប្រជាពលរដ្ឋចូលរួមយ៉ាងច្រើនកុះករ។ នៅក្នុងឱកាលនោះ លោកអភិបាលបានមានប្រសាសន៍ប្រាប់ថា: “វាមានសារៈសំខាន់ណាស់ ដើម្បីឱ្យក្មេងចេះភាសាកំណើតរបស់គេ នឹងដើម្បីជួយឱ្យគេរៀនភាសាខ្មែរខ្លះៗ មុនឱ្យគេចូលរៀននៅសាលារដ្ឋ ព្រោះបើគេមិនចេះភាសាខ្មែរឥខ្លះៗ វាពិបាកចូលរៀនសាលារដ្ឋណាស់។ ម្យ៉ាងទៀត គេរៀនភាសាខ្មែរជាមួយគ្រួសារមានការលំបាក”។ លោកក៏បានបញ្ជាក់ទៀតថា: “ព្រោះយើងនៅប្រទេសកម្ពុជា យើងត្រូវជួយគេឱ្យរស់នៅក្នុងប្រទេសដោយសុខស្រួល ព្រោះវៀតណាមដែលរស់នៅទីនេះ ដែលមិនចេះភាសាខ្មែរសោះ ត្រូវគេធ្វើបាប រឺគេពិន័យ”។ លោកឪពុក ឡេអូ បានឱ្យដឹងដែរថា “មូលហេតុដែលធ្វើឱ្យយើងកសាងសាលានៅទីនេះ ដោយមានសំណូមពរពីឪពុកម្តាយរបស់ក្មេង ព្រោះពេលខ្ញុំមកថ្វាយអភិបូជា ១ ខែម្តង ហើយក្រោយអភិបូជា យើងមានការជួបជុំជាមួយយុវជននិងក្មេងៗ ប៉ុន្តែ យើងគ្មានកន្លែងសោះ។ ដូច្នេះ ឪពុកម្តាយគេនិយាយថា វាជាការល្អប្រសិនបើ យើងមានអគារមួយ។ ខ្ញុំបានប្រាប់ទៅគេថា: “សូមធ្វើគំរោងទៅលោកអភិបាល និងលោកបូជាចារ្យដែលទទួលខុសត្រូវ។ គេនិយាយថា គេនឹងធ្វើ។ ចំពោះលោកគ្រូអ្នកគ្រូដែលមកបង្រៀន លោកឪពុកបានបន្ថែមថា “គេធ្លាប់មានសាលារៀនធ្វើពីឈើ តែត្រូវលិចទឹករៀងរាល់ឆ្នាំ គ្រូមិនអាចមកបង្រៀនបាន ហើយសិស្សខ្លះទៅរៀនសាលាខាងក្រៅ។ ប៉ុន្តែ ពួកគេនៅតែបន្តការសិក្សា។ ប៉ុន្តែ ឥលូវគេមានអគារថ្មី”។ លោកឪពុក ឡេ វ៉ាន់ទីន អ្នកទទួលខុសត្រូវ ព្រះសហគមន៍វត្តចំប៉ាបានមានប្រសាសន៍ដោយក្តីត្រេកអរថា “សាលានៅទីនេះនឹងជួយពួកគេឱ្យមានកន្លែងជួបជុំគ្នា និងរៀនសូត្រ”។



ពិធីសម្ពោធសាលារៀន

Photo D.R

សរុបមក ជំនួយដ៏ថ្លៃថ្លានេះពិតជាមានសារៈប្រយោជន៍សំរាប់ក្មេងៗនៅកន្លែងនោះ។

លោកឪពុក អូមែរ

## វិចនានុក្រមមុខរបរ និង មគ្គុទេសក៍អំពីឧត្តមសិក្សា







តើមានក្មេងៗអាយុពី ១៥ ទៅ ២០ ឆ្នាំ ប៉ុន្មាននាក់ ដែលមិនដឹងថាត្រូវរើសយកមុខរបរអ្វីទៅថ្ងៃមុខ? ពួកគេតែងធ្វើតាមគំនិតរបស់ញាតិសន្តានខ្លួន។ ដោយយល់នូវកង្វះខាតនេះអង្គការSipar (023 216 001) បោះពុម្ពនូវសៀវភៅ២ក្បាលថែមទៀត ដើម្បីអាច ជួយដល់យុវជនយុវនារី រកឃើញផ្លូវផ្ទាល់ខ្លួនអំពីមុខរបរ។

វិចនានុក្រមមុខរបរ: ពិពណ៌នាយ៉ាងច្បាស់និងយ៉ាងសាមញ្ញអំពីមុខរបរជាង៨០។

មគ្គុទេសក៍អំពីឧត្តមសិក្សា និងការបណ្តុះបណ្តាលវិជ្ជាជីវះ: បង្ហាញអំពីគ្រឹះស្ថានជាង ១៤០ នៅក្នុងខេត្តទាំង ១៩។ សំរាប់គ្រឹះស្ថាននីមួយៗមានព័ត៌មានដូចតទៅ: ឈ្មោះ អាសយដ្ឋាន លេខទូរស័ព្ទ មុខជំនាញដែលគេបង្រៀន ការបរិច្ឆេទចូលរៀន លក្ខខណ្ឌចូលរៀន តំលៃសិក្សា និងអាហារូបករណ៍។ល។


រចនាទំព័រ: ឡាង ច័ន្ទណាង

រូបថតគ្រប: យូនី សេហ្វ

ការិយាល័យផ្សព្វផ្សាយពត៌មាន
ព្រះសហគមន៏កាតូលិក: ផ្ទះលេខ ២៥
ផ្លូវលេខ ២៤២ សង្កាត់បឹងប្រលិត ភ្នំពេញ
Tel/Fax: (855) 23 224 120
csc@catholiccambodia.org

អភិបាលគ្រប់គ្រង:
លោកអភិបាល អេមីល ដេតម្ប

អគ្គនាយក:
លោកបូជាចារ្យ អូមែរ ហ្សឺរ៉ាល់ដូ